ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២២ លេខ ៤ ខែធ្នូ ២០១៨ តម្លៃ ១.៥០០៛

# ការបង្កើនចំណេះដឹងផ្នែកស្ទែមនៅឧត្តមសិក្សាក្នុងប្រទេសកម្ពុជា

*យើងមានតែបច្ចេកវិទ្យាមួយមុខ គឺមិនគ្រប់គ្រាន់ទេ។ បច្ចេកវិទ្យា ត្រូវផ្សារភ្ជាប់ជាមួយសិល្បៈសេរី និងមនុស្សសាស្ត្រ ទើបអាចផ្តល់លទ្ធផលដែលបណ្តាលឲ្យចិត្តយើងពុះពោរទៅមុខបាន។*

(Steve Jobs 2011)



*ឥឡូវ និស្សិតកម្ពុជាជាច្រើន ចាប់អារម្មណ៍ខ្លាំងលើមុខវិជ្ជាស្ទែម (STEM)៖ ពិព័រណ៍វិទ្យាសាស្ត្រកម្ពុជា ប្រចាំឆ្នាំលើកទី១៤។ ភ្នំពេញ កក្កដា ២០១៨*

## សេចក្តីផ្តើម

ស្ទែម (STEM) ដែលជាអក្សរកាត់នៃវាក្យស័ព្ទ វិទ្យាសាស្ត្រ (S) បច្ចេកវិទ្យា (T) វិស្វកម្ម (E) និង គណិតវិទ្យា (M) បានក្លាយជាប្រធានបទចម្បងមួយនៃការពិភាក្សាវែកញែក និងជាពាក្យពេញនិយម សម្រាប់មនុស្សជាច្រើននៅជុំវិញពិភពលោក។ អ្នកកសាងគោលនយោបាយ បានមើលឃើញជំនាញស្ទែម ថាជា មធ្យោបាយមួយដែលអាចជួយអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យមានភាពប្រកួតប្រជែង។ ស្រដៀងគ្នានេះដែរ ពលករមានសមត្ថភាពខ្ពស់ផ្នែកស្ទែម តែងមានប្រៀបលើពលករឯទៀតនៅក្នុងទីផ្សារការងារ។ ចំណុចសំខាន់ទាំងនេះ បានជម្រុញឲ្យនិស្សិតចាប់អារម្មណ៍ និងជ្រើសយកស្ទែម ធ្វើជាមុខជំនាញសម្រាប់សញ្ញាបត្ររបស់ខ្លួន ហើយវាក៏បានជម្រុញឲ្យរដ្ឋាភិបាលបង្កើនវិនិយោគជាមូលធន លើវគ្គសិក្សាពាក់ព័ន្ធនឹងស្ទែម ទាំងនៅកម្រិតអប់រំទូទៅ និងនៅឧត្តមសិក្សា។

ដូចនៅប្រទេសឯទៀតដែរ កិច្ចប្រឹងប្រែងលើកកម្ពស់ការអប់រំ និងវិជ្ជាជីវៈផ្នែកស្ទែមនៅកម្ពុជាកន្លងមក បានធ្វើឡើងដោយសារមានកំណើនតួនាទីដ៏សំខាន់នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅក្នុងសង្គមដូចមានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយថ្នាក់ជាតិសំខាន់ៗ។ ក្នុងនេះ ឯកសារគោលនយោបាយស្នូលមួយគឺគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២៥ បានចាប់អនុវត្តនៅឆ្នាំ២០១៥ដើម្បីប្រែក្លាយកម្ពុជាពីប្រទេសមានសេដ្ឋកិច្ចប្រើកម្លាំងពលកម្មមានជំនាញទាប ឲ្យទៅជាប្រទេសមានសេដ្ឋកិច្ចប្រើកម្លាំងពលកម្មមានជំនាញខ្ពស់ មានតម្លៃបន្ថែមខ្ពស់ និងមានសមត្ថភាពប្រកួតប្រជែងឲ្យបានមុនឆ្នាំ២០២៥ (Council

---

អត្ថបទនេះរៀបរៀងដោយ ឡេង ភីរម្យ ជាអ្នកស្រាវជ្រាវ និងប្រធានផ្នែកអប់រំ។ សូមយោងអត្ថបទនេះថា៖ Leng Phirom. 2018. "Building STEM Literacy in Cambodian Higher Education." *Cambodia Development Review* 22 (4): 1–6. Phnom Penh: CDRI.

## មាតិកា

ការបង្កើនចំណេះដឹងផ្នែកស្ទែមនៅឧត្តមសិក្សាក្នុងប្រទេសកម្ពុជា.......... ១
ការវិភាគយេនឌ័រពីអង្កេតលើយុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ គ្រួសារ សហគមន៍ ចំណេះដឹង ឥរិយាបថនយោបាយ និងការរំពឹងទុកទៅអនាគត.......... ៧
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស.......... ១២
– ស្ថានភាពក្នុងប្រទេស.......... ១៤
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI.......... ២០

of Ministers 2015)[១]។ គោលនយោបាយលើកកម្ពស់ និងពង្រឹងការអប់រំផ្នែកស្ទែម បានចាប់អនុវត្តមួយឆ្នាំក្រោយមកទៀត ដោយផ្តោតលើការពង្រឹងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សាក្នុងការផលិត និស្សិតបញ្ចប់ការសិក្សាដែលមានសមត្ថភាពចម្រុះ រួមទាំងជំនាញអភិវឌ្ឍន៍ខ្លួនឯង ជំនាញអនុវត្តន៍ និងជំនាញបច្ចេកទេស ដែលកម្ពុជាត្រូវការសម្រាប់ជួយទ្រទ្រង់សមត្ថភាពសេដ្ឋកិច្ចជាតិ។ សារៈសំខាន់នៃស្ទែម ពិតជាពិបាកនឹងរៀបរាប់អស់ណាស់។ សម្តេចនាយករដ្ឋមន្ត្រី បានបញ្ជាក់ឡើងវិញនាពេលថ្មីៗនេះទៀតពី ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការជម្រុញការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយបានលើកថា *"ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នឹងជួយជម្រុញផលិតភាព កំណើន ចំណេះដឹង និងសមត្ថភាពបច្ចេកទេស ដែលនឹងជួយប្រទេសកម្ពុជាក្នុងការកសាងសង្គមមួយ មានលក្ខណៈផ្អែកលើចំណេះដឹង"* (CDRI 2018, 1)។

ទោះបីមានការប្តេជ្ញាចិត្តខ្ពស់យ៉ាងនេះក្តី ស្ទែម នៅតែជាវាក្យសព្ទថ្មីសម្រាប់កម្ពុជា និងមានអត្ថន័យខុសគ្នាទៅតាមមនុស្សម្នាក់ៗ។ ទោះបី ស្ទែម មានការប្រើប្រាស់យ៉ាងទូលំទូលាយក្តី ឯកសារគោលនយោបាយនានា កម្រមានការកំណត់និយមន័យនៃវាក្យសព្ទនេះណាស់ ហើយបើសិនជាមានកំណត់ ក៏មិនបានលំអិតច្បាស់លាស់ដែរ។ ទាំងគោលនយោបាយស្ទែម និងចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ នៅតែចាត់ទុកស្ទែមជាមុខវិជ្ជាដាច់ៗពីគ្នាសម្រាប់ការបង្រៀននៅក្នុងថ្នាក់។ ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៤-១៨ និងផែនទីបង្ហាញផ្លូវឧត្តមសិក្សាឆ្នាំ២០៣០ មានលើកពីស្ទីម (STEAM) (វិទ្យាសាស្ត្រ (S) បច្ចេកវិទ្យា (T) វិស្វកម្ម (E) សិល្បៈ (A) និងគណិតវិទ្យា (M)) ប៉ុន្តែគ្រាន់តែគូសបញ្ជាក់ថា មុខវិជ្ជាដែលជាប់ទាក់ទងនឹងសិល្បៈ មានសារៈសំខាន់ស្មើគ្នា។ម៉្យាងទៀតគ្មានឯកសារគោលនយោបាយណាមួយក្នុងចំណោមឯកសារគោលនយោបាយទាំងនោះ បានពិភាក្សាពីស្ទែម ឬ ស្ទីម ក្នុងលក្ខណៈជាលំនាំបញ្ចូលគ្នាថ្មីមួយដែលមានចំណេះដឹងផ្នែកស្ទែម ជាគោលដៅចម្បងមួយនោះទេ។ ចំណុចនេះបង្ហាញឲ្យឃើញពី កង្វះខាតនិយមន័យច្បាស់លាស់សម្រាប់ពាក្យ "ស្ទែម" និងសម្រាប់គោលគំនិតជាប់ទាក់ទិនផ្សេងៗទៀត និងបានចោទជាសំណួរពីអត្ថន័យពិតប្រាកដនៃវាក្យសព្ទនេះ និងថា តើកម្ពុជាអាចពង្រឹងគុណភាពនិស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែមរបស់ខ្លួនបានដោយរបៀបណា (ដោយមិនទាន់រៀបរាប់ដល់ការយល់ដឹងទៅតាមបរិបទជាក់លាក់ផង) ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងប្រទេស និងក្នុងសកលលោកដែលកំពុងមានការផ្លាស់ប្តូរយ៉ាងលឿន។

ឯកសារនេះ ផ្អែកលើការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដើម្បីពិនិត្យឡើងវិញនូវកម្មវិធីស្ទែមសម័យថ្មីនៅកម្រិតឧត្តមសិក្សានៅកម្ពុជា។ ដំបូង ឯកសារនេះ រៀបរាប់ពីទិដ្ឋភាពនៃការសិក្សាដោយសង្ខេប។ បន្ទាប់មក ឯកសារនេះ ពិពណ៌នាពី គោលការណ៍ជាគោលគំនិត សម្រាប់ការអប់រំផ្នែកស្ទែមដែលមានរួមបញ្ចូលមុខវិជ្ជាផ្សេងៗទៀត ដើម្បីស្វែងយល់ពីការបង្រៀន និងការរៀនមុខវិជ្ជាស្ទែមក្នុងគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ដោយផ្តោតលើ ជំហានដែលសម្រេចបានកន្លងមកដើម្បីទទួលបានជោគជ័យ ក្នុងការបង្កើនចំណេះដឹងផ្នែកស្ទែម។ នៅផ្នែកខាងចុងនៃឯកសារនេះ មានការផ្តល់មតិមួយចំនួនសម្រាប់ការសិក្សានាពេលអនាគត។

## ការសិក្សារបស់យើង

ឯកសារនេះ បំពេញបន្ថែមលើការសិក្សាខ្នាតធំមួយពីការអប់រំផ្នែកស្ទែមនៅឧត្តមសិក្សាកម្ពុជា ដែលធ្វើឡើងដោយក្រុមសិក្សាស្រាវជ្រាវផ្នែកអប់រំនៃវិទ្យាស្ថាន CDRI ចាប់ពីខែឧសភា ដល់វិច្ឆិកា ២០១៧ នៅគ្រឹះស្ថានឧត្តមសិក្សាចំនួន ១៥។ ទិន្នន័យ ត្រូវបានប្រមូលពីឯកសារ និងសម្ភាសន៍ពាក់កណ្តាលរៀបរយជាង ១០០ ដែលធ្វើឡើងជាមួយអ្នកតាក់តែងគោលនយោបាយ អ្នកអប់រំ និស្សិត និងនិយោជកនៅកម្ពុជា ដោយពិនិត្យលើកម្មវិធីស្ទែមតាមផ្នែកខុសៗគ្នា រួមមាន វិទ្យាសាស្ត្រកសិកម្ម បច្ចេកវិទ្យាព័ត៌មាន ជីវវិទ្យា គីមីវិទ្យា គណិតវិទ្យា វិទ្យាសាស្ត្រសុខាភិបាល វិទ្យាសាស្ត្របរិស្ថាន និងវិស្វកម្ម។

## ចំណេះដឹងផ្នែកស្ទែមជាលំនាំថ្មីមួយ

ការអប់រំផ្នែកស្ទែម ដោយបង្រៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដោយឡែកៗពីគ្នា មានប្រវត្តិយូរយារណាស់មកហើយ។ ប៉ុន្តែក្នុងលក្ខណៈជាលំនាំថ្មី ស្ទែម ទើបត្រូវបានលើកយកមក ពិភាក្សាវែកញែកជាសាធារណៈ នៅទសវត្សរ៍១៩៩០ ប៉ុណ្ណោះ។ ពីដំបូង គេប្រើវាក្យសព្ទនេះ គ្រាន់តែដើម្បីសំដៅលើសារៈសំខាន់នៃមុខវិជ្ជានីមួយៗ ក្នុងគោលបំណងកសាងសេដ្ឋកិច្ចជាតិ ឲ្យមានសមត្ថភាពប្រកួតប្រជែង និងមានកម្លាំងពលកម្មមានជំនាញ និងមានលក្ខណៈសម្បត្តិអាចរកការងារធ្វើបានប៉ុណ្ណោះ (Chesky and Wolfmeyer 2015)។ គោលបំណងបែបនេះ បានដាក់កំហិតលើបែបបទនៃការប្រព្រឹត្តទៅនៃកម្មវិធីស្ទែម ពោលគឺ វាមិនត្រឹមតែពង្រឹងវិធីបង្រៀនតាមបែបបុរាណ ដែលត្រូវពឹងផ្អែកជាសំខាន់លើសមត្ថភាពគ្រូនោះទេ (គ្រូជាស្នូល) ប៉ុន្តែថែមទាំងធ្វើឲ្យយើងមើលរំលងនូវភាពជាប់ទាក់ទងគ្នា ឬភាពបញ្ចូលគ្នារវាងមុខវិជ្ជាទាំងនេះ នៅក្នុងស្ថានភាពជាក់ស្តែង។

[១] គោលនយោបាយជាតិសំខាន់ៗជាប់ទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមមាន ផែនការមេផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាឆ្នាំ២០១៣ សម្រាប់អនុវត្តទូទាំងប្រទេសកម្ពុជាពីឆ្នាំ២០១៤-២០ និងផែនការមេផ្នែកបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) កម្ពុជាឆ្នាំ២០១៤ សម្រាប់ឆ្នាំ២០២០។ រដ្ឋាភិបាល ក៏បានបង្កើតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅឆ្នាំ២០១៤ និងអគ្គលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សានេះនៅឆ្នាំ២០១៥ ដែរ។

ជាលទ្ធផល វាបានធ្វើឲ្យជំនាញរឹងមួយចំនួនមាន អាទិភាពជាងជំនាញទន់ ដូចជា ការធ្វើការជាក្រុម ការវិភាគស៊ីជម្រៅ ភាពច្នៃប្រឌិត និងការកសាងគុណតម្លៃ និងគុណធម៌ផ្សេងៗ (មេត្តាធម៌ និង ទំនួលខុសត្រូវតាមក្រមសីលធម៌ ជាដើម)។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលមានមតិលើកឡើងថា និស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែម នៅមានកង្វះខាតផ្នែកបញ្ញាស្មារតី គុណតម្លៃផ្ទាល់ខ្លួន និងទំនួលខុសត្រូវក្នុងសង្គម។

ក្នុងកិច្ចប្រឹងប្រែងធ្វើឲ្យនិស្សិត មានតុល្យភាពល្អរវាងជំនាញទន់នឹងជំនាញរឹង ការអប់រំផ្នែកស្ទែម បានប្រែក្លាយជាបណ្តើរៗទៅជាលំនាំបញ្ចូលគ្នាមួយដែលមានគោលដៅផលិត និស្សិតបញ្ចប់ការសិក្សាប្រកបដោយជំនាញ ចំណេះដឹង គុណតម្លៃ និងគុណធម៌សម្រាប់សតវត្សរ៍ទី២១។ លំនាំដែលគេហៅថា ចំណេះដឹងផ្នែកស្ទែម ដែរនោះ (Bybee 2013) តម្រូវឲ្យមានកម្មវិធីសិក្សាអន្តរមុខវិជ្ជាស្ទែមដែល "ស្វែងរកការបង្រៀន និងការរៀនរវាង/ក្នុងចំណោមមុខវិជ្ជាស្ទែមពីរ ឬច្រើនមុខ និង/ឬ រវាងមុខវិជ្ជាស្ទែមមួយមុខ រួមជាមួយនឹងមុខវិជ្ជាដទៃមួយមុខ ឬច្រើនមុខទៀត (Sanders 2009, 21)"។ នៅកម្រិតឧត្តមសិក្សា កម្មវិធីស្ទែមដែលមានរួមបញ្ចូលមុខវិជ្ជាផ្សេងៗទៀតនេះ បានសង្កត់ធ្ងន់លើការដាក់បញ្ចូលមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ/សិល្បៈ។ ដោយឡែកវិធីសាស្ត្រគរុកោសល្យ ត្រូវតែមានការត្រិះរិះវិភាគ និងលក្ខណៈជឿនលឿន ក្នុងនោះមានទាំងអន្តរកម្មរវាងនិស្សិត នឹងគ្រូបង្រៀនផងដែរ។ ការសិក្សាតាមបែបដោះស្រាយបញ្ហា ឬការសិក្សាដោយផ្អែកលើគម្រោង ក៏សំខាន់ណាស់ដែរ ក្នុងការផ្តល់ឲ្យនិស្សិតនូវបទពិសោធន៍ក្នុងស្ថានភាពជាក់ស្តែង ជាបន្ថែមលើការរៀនពីទ្រឹស្តីនៅក្នុងថ្នាក់រៀន។ សរុបមក ការកសាងចំណេះដឹងផ្នែកស្ទែម ត្រូវមានការតភ្ជាប់គ្នាយ៉ាងរឹងមាំរវាង សេចក្តីប្រកាសពីចក្ខុវិស័យ និងបេសកកម្ម ជាមួយនឹងការអនុវត្តជាក់ស្តែងរបស់សាកលវិទ្យាល័យ ជាពិសេសក្នុងវិធីសាស្ត្រគរុកោសល្យដែលបានយកមកប្រើប្រាស់ និងខ្លឹមសារនៃ កម្មវិធីសិក្សាដែលបានយកមកបង្រៀន ដូចមានសង្ខេបក្នុង រូបភាព១។

រូបភាព១៖ គោលគំនិតស្នូលនៃចំណេះដឹងផ្នែកស្ទែម




## លទ្ធផលសំខាន់ៗ

### *គោលបំណងនៃកម្មវិធីស្ទែម*

បេសកកម្មនៃឧត្តមសិក្សានៅកម្ពុជាគឺ "កសាងប្រព័ន្ធឧត្តមសិក្សាមួយប្រកបដោយគុណភាព ដើម្បីអភិវឌ្ឍធនធានមនុស្សឲ្យមានចំណេះដឹង ជំនាញ និងសីលធម៌ខ្ពស់សម្រាប់ធ្វើការងារ និងរស់នៅក្នុងយុគសម័យនៃសាកលភាវូបនីយកម្ម និងសង្គមពុទ្ធិ" (MOEYS 2014, 3)។ ចេតនានេះ អាចមើលឃើញច្បាស់ក្នុងអន្តរាគមន៍ជាគោលនយោបាយជាតិសំខាន់ៗចំនួនពីរ។ គោលនយោបាយជាតិទី១ គឺ កម្មវិធីឆ្នាំមូលដ្ឋាន បានចាប់អនុវត្តនៅពាក់កណ្តាលទសវត្សរ៍ទី១ នៃសតវត្សទី២១ ដែលយើងអាចនិយាយបានថា វាមានឫសគល់ក្នុងទស្សនវិជ្ជាបែបសិល្បៈសេរី និងតម្រូវឲ្យនិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី១ រៀនវគ្គសិក្សាមូលដ្ឋាន មានដូចជា វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម មនុស្សសាស្ត្រ និងភាសាបរទេស មុននឹងឈានទៅដល់ជំនាញឯកទេសរបស់ខ្លួន។ គោលនយោបាយជាតិទី២ គឺ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ដែលបានចាប់អនុវត្តនៅឆ្នាំ២០១២ ដើម្បីផ្តល់ការណែនាំសម្រាប់ការអភិវឌ្ឍការអប់រំនៅគ្រប់កម្រិត។ នៅកម្រិតឧត្តមសិក្សា CQF គូសបញ្ជាក់ពីការផលិតនិស្សិតបញ្ចប់ការសិក្សាប្រកបដោយចំណេះដឹង ជំនាញទំនាក់ទំនងអន្តរបុគ្គល ចំណេះដឹងផ្នែកឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ជំនាញលេខនព្វន្ត និងសីលធម៌ជាពលរដ្ឋល្អ។

ការដាក់បញ្ចូលថ្នាក់ឆ្នាំមូលដ្ឋាន និងប្រព័ន្ធផ្ទេរក្រេឌីតទៅក្នុងកម្មវិធី ថ្នាក់បរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ជាគោលការណ៍វាបានបង្ហាញពីភាពស្របគ្នាជាមួយនឹង គោលដៅអប់រំថ្នាក់ជាតិ ពោលគឺ ការផលិតនិស្សិតបញ្ចប់ការសិក្សាដែលមានសមត្ថភាពចូលរួមចំណែកយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងនយោបាយរបស់ប្រទេសជាតិ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា គោលដៅនៃកម្មវិធីស្ទែមក្នុងសាកលវិទ្យាល័យទាំង ១៥ ដែលក្រុមស្រាវជ្រាវបានធ្វើអង្កេត សុទ្ធតែមានលក្ខណៈស្របតាមចក្ខុវិស័យឧត្តមសិក្សាថ្នាក់ជាតិ។

យ៉ាងណាមិញ គោលនយោបាយស្ទែមដែលបានចាប់អនុវត្តក្នុងឆ្នាំ២០១៥ មានទិសដៅចង្អៀត និងជួយគាំទ្រជាសំខាន់ដល់តែផែនការថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដូចមានកំណត់ក្នុង គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២៥។ ការសង្កត់ធ្ងន់លើវិធីសាស្ត្រប្រយោជន៍និយមបែបនេះ មានន័យថា គោលដៅនៃគោលនយោបាយស្ទែម បានមើលរំលង ទិដ្ឋភាពសង្គមវប្បធម៌នៃ ការអប់រំដែលមានគូសបញ្ជាក់ក្នុង ចក្ខុវិស័យជាតិ សម្រាប់ឧត្តមសិក្សានៅកម្ពុជា និង

ក្នុងបេសកកម្ម និងគោលដៅរបស់គ្រឹះស្ថានឧត្តមសិក្សា បានចុះធ្វើអង្កេតទាំង ១៥។

## គរុកោសល្យផ្នែកស្នែម និងខ្លឹមសារកម្មវិធីសិក្សា

ទោះបីគោលដៅនៃឧត្តមសិក្សាកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ស្ថាប័ន មានលក្ខណៈស្របតាមគោលដៅនៃចំណេះដឹងផ្នែកស្ទែមក្ដី ក៏ចក្ខុវិស័យ និងបេសកកម្មដែលផ្សារភ្ជាប់ជាមួយចំណេះដឹងផ្នែកស្ទែម នៅតែមានភាពខុសគ្នាជាមួយនឹង វិធីសាស្ត្រគរុកោសល្យ និងកម្មវិធីសិក្សានៅក្នុងការអប់រំផ្នែកស្ទែម។ ក្នុងការពិតជាក់ស្ដែង ការបង្រៀន និងរៀនផ្នែកស្ទែម នៅតែមានការរាំងស្ទះដោយសារទម្លាប់គិតគូរដោយផ្នែកៗ (silo mentality)។ ការដាក់អនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងប្រព័ន្ធផ្ទេរក្រេឌីតទទួលបានលទ្ធផលចម្រុះ ដោយហេតុថា គ្រឹះស្ថានឧត្តមសិក្សាភាគច្រើនផ្ដល់នូវ វគ្គសិក្សាផ្អែកលើកម្មវិធីសិក្សាបែបបញ្ញត្តិ ហើយជម្រើសដែលផ្ដល់ឲ្យនិស្សិតនោះ វាមានចំនួនតិចតួច ឬខ្វះភាពបត់បែន។ នៅកម្ពុជា ការអនុវត្តកម្មវិធីស្ទែមដែលមានរួមបញ្ចូលមុខវិជ្ជាផ្សេងៗ ជួបនឹងបញ្ហាប្រឈមជាច្រើនដូចមានអធិប្បាយខាងក្រោម៖

## *វិធីសាស្ត្របង្រៀនបុរាណយកគ្រូធ្វើជាស្នូល*

ការបង្រៀនឯកទិសក្នុងថ្នាក់រៀន នៅតែជាវិធីសាស្ត្របង្រៀនគោល នៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដោយក្នុងនេះ គេចាត់ទុកគ្រូជាឃ្លាំង និងជាអ្នកចែកចាយចំណេះដឹង។នៅតាមគ្រឹះស្ថានឧត្តមសិក្សាជាច្រើន អន្តរកម្មរវាងនិស្សិតនឹងនិស្សិត ក៏ដូចជា រវាងនិស្សិតនឹងគ្រូ នៅមានកម្រិតនៅឡើយ ហើយនិស្សិតបញ្ចប់ការសិក្សា បានត្រឹមក្លាយជាកម្លាំងពលកម្មចាំតែស្ដាប់បង្គាប់ ជាជាងកម្លាំងពលកម្មដែលមានសមត្ថភាព (ដូចជា ការរួមសហការគ្នា (collaboration) ការច្នៃប្រឌិត (creativity) ការវិភាគស៊ីជម្រៅ (critical thinking) និងការប្រាស្រ័យទាក់ទង (communication) ដែលគេហៅកាត់ថា "C៤")) សម្រាប់សតវត្សរ៍ទី២១។ ឧបសគ្គមួយដែលរារាំងភាពច្នៃប្រឌិត និងនវានុវត្តន៍របស់និស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែម គឺកង្វះខាតការយល់ដឹងផ្នែកសិល្បៈ និងមនុស្សសាស្ត្រ ដែលជាលទ្ធផលនៃកម្មវិធីសិក្សាមិនមានភាពបត់បែន និងមិនមានជម្រើសអន្តរមុខវិជ្ជាគ្រប់គ្រាន់។ ការអនុវត្តប្រព័ន្ធផ្ទេរក្រេឌីត គឺដើម្បីផ្ដល់ជម្រើស និងភាពបត់បែនដល់និស្សិតទាំងក្នុងមុខវិជ្ជាស្នូល និងមុខវិជ្ជាជ្រើសរើស។ ជាក់ស្ដែង សាកលវិទ្យាល័យដែលបានទទួលជោគជ័យក្នុងកិច្ចការនេះ នៅមានចំនួនតិច ដោយសារការជ្រើសរើសមុខវិជ្ជាសិក្សានៅតាមគ្រឹះស្ថានអប់រំភាគច្រើន នៅមានលក្ខណៈបែបបញ្ញត្តិ សូម្បីកម្មវិធីសិក្សាឆ្នាំមូលដ្ឋាន ក៏គេបានសង្កេតឃើញថា គ្រាន់តែជាស្ពានចម្លងនិស្សិតពីវិទ្យាល័យទៅសាកលវិទ្យាល័យប៉ុណ្ណោះ គឺមិនមែនជាការបន្ថែមតម្លៃដោយផ្សារភ្ជាប់មុខវិជ្ជាវិទ្យាសាស្ត្រ ជាមួយនឹងសិល្បៈ/មនុស្សសាស្ត្រ នោះឡើយ។ មួយវិញទៀត និយោជកជាច្រើនបានត្អូញត្អែរពីកង្វះខាតជំនាញទន់ (ដូចជា ស្មារតីរួមក្រុម និងការប្រាស្រ័យទាក់ទង ជាដើម) របស់និស្សិតបញ្ចប់ការសិក្សា។ យោងតាមមតិខ្លះ និស្សិតបញ្ចប់ការសិក្សា តាមធម្មតាត្រូវការពេលយ៉ាងហោចណាស់ពីបីទៅប្រាំមួយខែ ដើម្បីសម្របខ្លួនទៅនឹងកន្លែងធ្វើការ។

បញ្ហាមួយទៀត ដែលការស្រាវជ្រាវនេះបានគូសរំលេច គឺឱកាសដ៏តិចតួចក្នុងការអភិវឌ្ឍវិជ្ជាជីវៈ សម្រាប់សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសកម្ពុជា។ ទោះបីគន្លងនៃការបង្រៀនថ្មី តាមបែបការសិក្សាដោយផ្អែកលើគម្រោង ឬការចុះកម្មសិក្សា មានចែងច្បាស់ក្នុងក្របខ័ណ្ឌគុណវឌ្ឍជាតិកម្ពុជាក្ដី គឺមានគ្រូបង្រៀនតិចនាក់ណាស់ដែលបានអនុវត្តវិធីសាស្ត្រថ្មីៗទាំងនេះនៅក្នុងកម្មវិធីសិក្សារបស់គាត់។ ម៉្យាងទៀត គ្រូបង្រៀនភាគច្រើន បានទទួលការអប់រំនៅក្នុងស្រុក និងតាមបែបបុរាណ ដូច្នេះហើយ គាត់មានបទពិសោធន៍តិចតួច ឬក៏គ្មានសោះក្នុងការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបយកសិស្សធ្វើជាចំណុចស្នូល។ ក្នុងដំណើរក្លាយជាគ្រូបង្រៀន គាត់គ្រាន់តែអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមទម្លាប់ដដែលៗតែប៉ុណ្ណោះ។

## *កង្វះខាតក្នុងការរួមបញ្ចូល បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍*

ក្នុងពេលពិភពលោកកំពុងបង្កើនការប្រើប្រាស់ប្រព័ន្ធឌីជីថលរួមជាមួយនឹងការអភិវឌ្ឍឧស្សាហកម្ម ៤.០ និងបញ្ញាសិប្បនិម្មិតដ៏មានសន្ទុះ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ នៅតែមិនទាន់ទទួលបានការផ្ដល់សារៈសំខាន់នៅក្នុងកម្មវិធីសិក្សា និងក្នុងប្រតិបត្តិការរបស់គ្រឹះស្ថានឧត្តមសិក្សា។ ក្រៅពីធនធានមិនទាន់មានគ្រប់គ្រាន់ សាស្ត្រាចារ្យជាច្រើននាក់ពុំទាន់បានទទួលការបណ្ដុះបណ្ដាលពី ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបឌីជីថលនៅឡើយ។ ស្ថានភាពនេះជាក្ដីបារម្ភមួយ ព្រោះកង្វះចំណេះដឹងផ្នែកឌីជីថល កំពុងរារាំងសាស្ត្រាចារ្យ និងនិស្សិត ក្នុងការចូលប្រើប្រាស់ធនធានដ៏សម្បូរបែបនៅក្នុងប្រព័ន្ធអ៊ីនធើណិត។ ទោះបីប្រជាជនកម្ពុជាជាង ៥០% មានទូរស័ព្ទឆ្លាតប្រើប្រាស់ក្ដី (គិតត្រឹមឆ្នាំ២០១៦) កង្វះចំណេះដឹងផ្នែកឌីជីថល កំពុងបន្សោយនូវកិច្ចប្រឹងប្រែងរបស់កម្ពុជា ក្នុងការពង្រីកលទ្ធភាពចូលរៀនថ្នាក់ឧត្តមសិក្សារបស់ប្រជាជនទូទៅ (ក្នុងនោះ ប្រជាជន ៧០% មានអាយុក្រោម ៣០ឆ្នាំ) (Phong, Lihol and Sola 2016)។

## *មាតិកានៃកម្មវិធីសិក្សាចាស់ហួសសម័យ និងផ្អែកតាមមុខវិជ្ជា*

មាតិកានៃការអប់រំផ្នែកស្ទែមនៅកម្ពុជា មានលក្ខណៈផ្អែកតាមមុខវិជ្ជាខ្លាំង ដោយនិស្សិតភាគច្រើនមានទំនោរក្នុងការរៀនជំនាញបច្ចេកទេសដែលចាំបាច់សម្រាប់អាជីពរបស់ខ្លួន ជាជាងជំនាញផ្សេងទៀត។ មាតិកានៃមុខវិជ្ជាស្នូលមួយចំនួន ដូចជា គណិតវិទ្យា រូបវិទ្យា ជីវវិទ្យា និងគីមីវិទ្យា គឺចាស់ហួសសម័យអស់ទៅហើយ។ គ្រូបង្រៀនក្នុងមុខវិជ្ជាស្ទើរតែទាំងអស់ ប្រើប្រាស់តែសៀវភៅមេរៀនផលិតក្នុងស្រុក (ដែលចងក្រងចេញពីឯកសារ និងមាតិកា

សម្រាប់ការប្រើប្រាស់ក្នុង បរិស្ថានបង្រៀននៅឯបរទេស) និងបំពេញបន្ថែមដោយសៀវភៅសិក្សាជាភាសាបរទេសដែលនាំចូលពីក្រៅប្រទេស។ លក្ខណៈនេះជាឫសគល់នៃបញ្ហា មាតិកាកម្មវិធីសិក្សាមិនមានភាពជាប់ទាក់ទងគ្នាល្អជាមួយនឹង ទីផ្សារការងារដែលមានការផ្លាស់ប្តូរយ៉ាងលឿន និងជាមួយសង្គមទូទៅ។ ម៉្យាងទៀត សាស្ត្រាចារ្យសាកលវិទ្យាល័យជាច្រើននាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ មានបទពិសោធន៍តិចតួចក្នុងការស្រាវជ្រាវ ដូច្នេះសមត្ថភាពរបស់គាត់ដើម្បីចូលរួមកែសម្រួលកម្មវិធីសិក្សា គឺនៅមានកម្រិត។ សូម្បីអ្នកមានបទពិសោធន៍ស្រាវជ្រាវ ក៏សឹងតែមិនបានធ្វើទំនើបកម្មមេរៀនរបស់ខ្លួនដែរ ដោយសារបន្ទុកការងារបង្រៀនដ៏ច្រើននៅក្នុងគ្រឹះស្ថានអប់រំមួយ ឬច្រើនដែលគាត់ចូលបម្រើការងារ ហើយបញ្ហានេះមានចោទឡើងដដែលៗនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

### ***កង្វះខាតសម្ភារបរិក្ខារនៅបណ្ណាល័យ និងមន្ទីរពិសោធន៍***

បណ្ណាល័យនៅតាមគ្រឹះស្ថានឧត្តមសិក្សាភាគច្រើន មានធនធានមិនគ្រប់គ្រាន់ទេ។ សៀវភៅភាគច្រើន គឺជាអំណោយពីដៃគូអភិវឌ្ឍន៍ និងអង្គការសប្បុរសធម៌ផ្សេងៗ។ ឯកសារបម្រើការសិក្សាដែលមិនសូវជាប់ទាក់ទងនឹងស្ថានភាពពិតក្នុងស្រុកបែបនេះ បានចោទជាបញ្ហាប្រឈម ដែលប៉ះពាល់ដល់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជម្រុញឲ្យប្រជាពលរដ្ឋមានវប្បធម៌អាន និងស្រាវជ្រាវ។ បញ្ហានេះមិនទាន់និយាយដល់វប្បធម៌អានដែលនៅខ្វះខាតខ្លាំងក្នុងសង្គមកម្ពុជា ជាពិសេសក្នុងចំណោមនិស្សិតផង។ និស្សិតឆ្លើយសម្ភាសន៍ក្នុងការសិក្សាស្រាវជ្រាវនេះ បានប្រាប់ថា គាត់ប្រើប្រាស់បណ្ណាល័យតែម្តង ឬពីរដងប៉ុណ្ណោះក្នុងមួយសប្តាហ៍ ហើយជាទូទៅ គឺនៅពេលមានការលុបចោលម៉ោងរៀនធម្មតារបស់គាត់។ ម៉្យាងទៀត ការបង្រៀន និងរៀនផ្នែកវិទ្យាសាស្ត្រ ជួបការលំបាកច្រើន ដោយសារកង្វះមន្ទីរពិសោធន៍ទំនើប បំពាក់ដោយបច្ចេកវិទ្យាថ្មីៗ ហើយចំណុចនេះបានប៉ះពាល់ជាខ្លាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា។

### ***បញ្ហាគុណភាពក្នុងកម្មវិធីស្ទែម***

លទ្ធភាពទទួលបានការអប់រំស្ទែម ជាបញ្ហាមួយស្មុគស្មាញ។ កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីបង្កើនចំណាប់អារម្មណ៍របស់និស្សិតលើមុខវិជ្ជាទាំងនេះ បានជះឥទ្ធិពលដល់គុណភាពអប់រំ ជាពិសេសក្នុងវិស័យឯកជន។ នៅតាមវិទ្យាល័យ និស្សិតភាគច្រើន បានជ្រើសយកផ្នែកសិក្សាវិទ្យាសាស្ត្រ ប៉ុន្តែនៅពេលគាត់ឡើងដល់កម្រិតឧត្តមសិក្សា ស្ថានភាពនេះបានប្រែប្រួលផ្ទុយគ្នាស្រឡះ។ នៅតាមសាកលវិទ្យាល័យនានា សិស្សបញ្ចប់វិទ្យាល័យភាគច្រើន រួមទាំងសិស្សពូកែខាងគណិតវិទ្យា និងវិទ្យាសាស្ត្រផង បែរជាជ្រើសយកមុខវិជ្ជាវិទ្យាសាស្ត្រសង្គមទៅវិញ។ ដូច្នេះ ដើម្បីពង្រីកលទ្ធភាពបានចូលរៀនថ្នាក់ឧត្តមសិក្សា និងដោះស្រាយបញ្ហាការចុះឈ្មោះចូលរៀននោះ គ្រឹះស្ថានឧត្តមសិក្សាជាច្រើន បានបន្ទាបលក្ខខណ្ឌទទួលនិស្សិតចូលរៀន ហើយបានទាក់ទាញទាំងនិស្សិតមានសមត្ថភាពខ្ពស់ និងនិស្សិតមានសមត្ថភាពទាប ឲ្យចូលរៀនក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន។ ម៉្យាងទៀត ដើម្បីជួយសម្រួលដល់សមត្ថភាពខុសៗគ្នារបស់និស្សិត គ្រឹះស្ថានឧត្តមសិក្សាក៏បានកែសម្រួលកម្មវិធីស្ទែម និងមាតិកាកម្មវិធីសិក្សា។ ទង្វើបែបនេះបានប៉ះពាល់យ៉ាងខ្លាំងដល់គុណភាពនៃការអប់រំស្ទែម។

## **ការផ្តល់មតិ**

កិច្ចពិភាក្សាខាងលើ បានបង្ហាញពីបញ្ហាស្មុគស្មាញជាច្រើនដែលជាប់ទាក់ទងនឹង ការបង្កើនចំណេះដឹងផ្នែកស្ទែមនៅកម្ពុជា និងបានគូសបញ្ជាក់ពីចំណុចស្នូលនៃបញ្ហាចោទ ពោលគឺ តើប្រទេសកម្ពុជាត្រូវធ្វើអ្វីខ្លះ ដើម្បីអាចផ្តល់នូវការអប់រំប្រកបដោយគុណភាពក្នុងរយៈពេលខ្លី និងអាចផលិតនិស្សិតបញ្ចប់ការសិក្សាដែលមានបទពិសោធន៍ច្រើន មានទំនួលខុសត្រូវជាពលរដ្ឋ និងមានសមត្ថភាព អាចជួយសម្រេចបានតាមចក្ខុវិស័យរបស់កម្ពុជាក្នុងការក្លាយជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។ យោងតាមលទ្ធផលរកឃើញ ការសិក្សានេះមានផ្តល់មតិសំខាន់ៗចំនួនប្រាំ ដើម្បីឲ្យកម្ពុជាសម្រេចបាននូវការបង្កើនចំណេះដឹងផ្នែកស្ទែម៖

***ចំណេះដឹងផ្នែកស្ទែមសម្រាប់កម្ពុជា៖*** គោលនយោបាយផ្នែកស្ទែម គួរមានការកែសម្រួលឡើងវិញ ដើម្បីដាក់បញ្ចូលទិដ្ឋភាពវប្បធម៌សង្គម ទៅក្នុងចក្ខុវិស័យនៃ គោលនយោបាយនេះ។ គរុកោសល្យប្រកបដោយនវានុវត្តន៍និងភាពជឿនលឿនដែលមានការគាំទ្រដោយ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ គួរមានដាក់បញ្ចូលទៅក្នុងកម្មវិធីស្ទែម ប៉ុន្តែការដាក់បញ្ចូលនេះ ត្រូវមានការសម្របសម្រួល និងការកែតម្រូវមួយចំនួន ដើម្បីឲ្យប្រាកដថា វាស៊ីគ្នាល្អជាមួយនឹងប្រព័ន្ធសង្គមកម្ពុជា។ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ក៏ត្រូវពិនិត្យឡើងវិញដែរនូវ មាតិកាកម្មវិធីសិក្សាផ្នែកស្ទែម ដោយរៀបចំឲ្យមានការចូលរួមពីសាស្ត្រាចារ្យ និយោជក និស្សិត និងឪពុកម្តាយរបស់និស្សិតផង។

***មជ្ឈមណ្ឌលសម្រាប់ជំរុញភាពល្អវិសេស៖*** គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវកសាងមជ្ឈមណ្ឌលមួយសម្រាប់ជម្រុញឲ្យការបង្រៀន និងការស្រាវជ្រាវមានភាពល្អវិសេស និងត្រូវបំពេញភារកិច្ចរបស់ខ្លួននៃការជួយគាំទ្រសាស្ត្រាចារ្យ និងអ្នកគ្រប់គ្រងរដ្ឋបាល ក្នុងការដាក់បញ្ចូលនវានុវត្តន៍ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងគរុកោសល្យបែបរិភាគ (critical pedagogy) ទៅក្នុងការបង្រៀន និងការរៀនផ្នែកស្ទែម។ ម៉្យាងវិញទៀត ពួកគាត់គួរទទួលបានការចែករំលែករបៀបអនុវត្តល្អៗ នៅអន្តរជាតិ ហើយសាកលវិទ្យាល័យ គួរមានការស្រាវជ្រាវពីបញ្ហាប្រឈមជាក់ស្តែងដែលគ្រូបង្រៀនត្រូវជួបប្រទះនៅក្នុងថ្នាក់រៀនផងដែរ។ មជ្ឈមណ្ឌលទាំងនេះ ដើរតួនាទីក្នុងការផ្តួចផ្តើមធ្វើកម្មវិធីផ្សព្វផ្សាយដែលផ្តល់ឱកាសឲ្យនិស្សិតអនុវត្តនូវ ចំណេះដឹងរបស់ខ្លួនក្នុងស្ថានភាពជាក់ស្តែង និងក្នុងការភ្ជិតគម្លាតរវាងសាលារៀននឹងកន្លែងធ្វើការ។

***ឧទ្យានវិទ្យាសាស្ត្រ៖*** ឧទ្យានវិទ្យាសាស្ត្រ បើកឱកាសឲ្យមានកិច្ចសហការរវាងរដ្ឋាភិបាលឧស្សាហកម្មនឹងគ្រឹះស្ថានឧត្តមសិក្សាក្នុងការលើកកម្ពស់វិទ្យាសាស្ត្រ និងនវានុវត្តន៍នៅកម្ពុជា។ ឧទ្យាននេះ នឹងជួយគ្រប់គ្រងលំហូរចំណេះដឹង និងគំនិតដែលផុសចេញពីការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ទៅដល់វិស័យឯកជនសម្រាប់ការធ្វើពាណិជ្ជកម្មលើការស្រាវជ្រាវ និងការអភិវឌ្ឍផលិតផល។ ប្រសិនបើមានការគ្រប់គ្រងល្អ ឧទ្យានវិទ្យាសាស្ត្រនឹងជួយសម្រួលដល់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍឧស្សាហកម្មដោយប្រើបច្ចេកវិទ្យាទំនើប ដូចអាចឃើញច្បាស់នៅតាមប្រទេសអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចកំពុងលេចធ្លោជាច្រើន។

***ប្រព័ន្ធអេកូឡូស៊ីជួយគាំទ្រការអប់រំស្ទែម៖*** ការអប់រំផ្នែកស្ទែមត្រូវការប្រព័ន្ធអេកូឡូស៊ី សម្រាប់ឧត្តមសិក្សាមួយដែលផ្តល់នូវការគាំទ្រ និងមានដំណើរការល្អ។ ដើម្បីជម្រុញឲ្យការបង្រៀន និងការរៀនផ្នែកស្ទែមមានបញ្ចូលមុខវិជ្ជាផ្សេងៗទៀត គ្រឹះស្ថានឧត្តមសិក្សា និងរដ្ឋាភិបាល ត្រូវពង្រឹងកម្មវិធីមួយចំនួន ដូចជាកម្មវិធីសិក្សាថ្នាក់មូលដ្ឋាន និងផ្តល់វគ្គសិក្សាជាច្រើនបន្ថែមទៀតមានជាអាទិ៍ សិល្បៈ និងមនុស្សសាស្ត្រ សម្រាប់និស្សិតផ្នែកស្ទែម។ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើតវគ្គសិក្សាថ្មីៗផ្សេងទៀត (ជាពិសេស សហគ្រិនភាព) និងដាក់បញ្ចូលវគ្គទាំងនោះទៅក្នុងកម្មវិធីសិក្សាមានស្រាប់ ដើម្បីឲ្យនិស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែមអាចក្លាយជាអ្នកបង្កើតការងារ មិនមែនគ្រាន់តែជាអ្នកស្វែងរកការងារធ្វើនោះទេ។ នៅជំហានខាងមុខទៀត វគ្គសិក្សាមិនមែនស្ទែមមួយចំនួនគឺគួរមានដាក់ឲ្យនិស្សិតផ្នែកស្ទែម រៀនជាចាំបាច់មុនពេលគាត់អាចទទួលបានសញ្ញាបត្រ។

គ្រឹះស្ថានឧត្តមសិក្សា គួរផ្តួចផ្តើមគំនិត ក្នុងការបង្កើតវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់បុគ្គលិកបង្រៀន និងបុគ្គលិកគាំទ្រ និងធ្វើឲ្យវគ្គបណ្តុះបណ្តាលទាំងនោះមានលក្ខណៈផ្លូវការ។ វិធីសាស្ត្រ ដូចជា ការរៀនដោយផ្អែកលើគម្រោង មិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការគាំទ្រពីអ្នកគ្រប់គ្រងរដ្ឋបាលដែលមានគំនិតបើកចំហ និងមានព័ត៌មានច្បាស់លាស់ ព្រោះវិធីសាស្ត្រទាំងនេះ ត្រូវមានគ្រូបង្រៀនដែលមានការប្តេជ្ញាចិត្ត ត្រូវមានប្រព័ន្ធសហការល្អ និងមានការផ្តល់ធនធានចាំបាច់និងគ្រប់គ្រាន់ដល់អ្នកអនុវត្ត។ សេវាកម្មនានាសម្រាប់ជួយគាំទ្រនិស្សិត ដូចជា បណ្ណាល័យ អាគារសម្រាប់ឲ្យនិស្សិតស្នាក់នៅ ការប្រឹក្សា និងការជួយណែនាំពីការងារនិងអាជីព ក៏ត្រូវមានដោយមិនអាចខ្វះបាន។ ទាំងអស់នេះ មានន័យថា គ្រឹះស្ថានឧត្តមសិក្សា គួរចាប់ផ្តើមគិតគូរពីការរីកចម្រើនរបស់និស្សិត ក្នុងលក្ខណៈជាមនុស្សពេញលេញ មិនមែនគ្រាន់តែជាអ្នកមកទិញជំនាញយកទៅប្រើប្រាស់នោះទេ។

***ស្ទែមសម្រាប់សិស្សឆ្នើម៖*** ចំណាប់អារម្មណ៍របស់សិស្សលើមុខជំនាញស្ទែម គួរតែបំផុសឡើងមែនហើយ ប៉ុន្តែ ស្ទែមក៏ត្រូវតែជាមុខវិជ្ជាសម្រាប់សិស្សពូកែ ឆ្នើមៗបំផុត និងមានមូលដ្ឋានគ្រឹះរឹងមាំផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា។ គ្រូពេទ្យដែលមិនមានសមត្ថភាពគ្រប់គ្រាន់ អាចនាំឲ្យមានការបាត់បង់ជីវិតដោយមិនសមហេតុផល រីឯវិស្វករខ្វះសមត្ថភាព អាចបណ្តាលឲ្យ សំណង់អាគារដួលរលំបាន។ គ្រឹះស្ថានឧត្តមសិក្សាគួរកំណត់វិធានការណ៍ផ្សេងៗ សម្រាប់ទាក់ទាញសិស្សឆ្នើមឲ្យជ្រើសយកមុខជំនាញស្ទែម ដោយរួមសហការជាមួយវិទ្យាល័យ។ វិធានការណ៍ទាំងនេះ មានដូចជា ការជួបសំណេះសំណាលជាទៀងទាត់ជាមួយអ្នកវិទ្យាសាស្ត្រ ដែលទទួលបានជោគជ័យ (បុគ្គលគំរូ) និង ការប្រកួតប្រជែងទូទាំងប្រទេសខាងផ្នែកវិទ្យាសាស្ត្រ និងនវានុវត្តន៍ ជាដើម។

## ឯកសារយោង


Bybee, Rodger W. 2013. *The Case for STEM Education: Challenges and Opportunities*. Arlington, VA: National Science Teachers Association Press.

CDRI (Cambodia Development Resource Institute). 2018. *Science and Technology for Industrialisation, Economic Growth and Development in Cambodia*. Cambodia Outlook Brief. Phnom Penh: CDRI.

Chesky, Nataly Z., and Mark R. Wolfmeyer. 2015. *Philosophy of STEM Education*. New York: Palgrave Macmillan.

Council of Ministers. 2015. *Industrial Development Policy 2015–2025: Market Orientation and Enabling Environment for Industrial Development*. Phnom Penh: Council of Ministers.

MOEYS (Ministry of Education, Youth and Sport). 2014. *Policy on Higher Education Vision 2030*. Phnom Penh: Ministry of Education, Youth and Sport.

Phong Kimchhoy, Srou Lihol and Javier Sola. 2016. *Research Report: Mobile Phones and Internet Use in Cambodia 2016*. Phnom Penh: United States Agency for International Development.

Sanders, Mark. 2009. "STEM, STEM Education, STEMmania." *Technology Teacher* 68 (4): 20–26.

# ការវិភាគយេនឌ័រពីអង្កេតលើយុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ គ្រួសារ សហគមន៍ ចំណេះដឹង ឥរិយាបថនយោបាយ និងការរំពឹងទុកទៅអនាគត

## សេចក្តីផ្តើម

ប្រទេសកម្ពុជា ឆ្លងតាមកំណើនគួរឲ្យស្ញប់ស្ញែងក្នុងជាងពីរទសវត្សរ៍កន្លងមកនេះ កំពុងក្លាយយ៉ាងលឿនជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី។ កម្ពុជាសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងលឿនគួរស្ញប់ស្ញែងក្នុង ២០ឆ្នាំកន្លងមក ដោយមាន កំណើន ផសស ជាប់រហូតដល់ជាង ៧% ក្នុងមួយឆ្នាំ ការពង្រីកនិងកែលំអហេដ្ឋារចនាសម្ព័ន្ធ និងការជឿនលឿនគួរឲ្យកត់សំគាល់ក្នុងការកាត់បន្ថយភាពក្រីក្រ។ លទ្ធផលសេដ្ឋកិច្ចសង្គមដ៏ល្អជាយូរឆ្នាំមកនេះ បានធ្វើឲ្យមាននគរូបនីយកម្មយ៉ាងលឿន ហើយស្របគ្នានឹងការប្រែប្រួលផ្នែកប្រជាសាស្ត្រ ក៏មានការកែលំអគុណភាពការអប់រំ និងកំណើនដែនគ្របដណ្តប់និងការប្រើប្រាស់អ៊ិនធើណិត ហើយទាំងអស់នេះបានធ្វើឲ្យប្រែប្រួលដល់ចំណាប់អារម្មណ៍ ការគិតគូរ និងអាកប្បកិរិយារបស់ពលរដ្ឋកម្ពុជា ជាពិសេស ក្នុងចំណោមស្ត្រី។

ពិតហើយ ស្ត្រីបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការកសាងប្រទេសកម្ពុជាឡើងវិញ ការអភិវឌ្ឍសេដ្ឋកិច្ច និងអនាគតរំពឹងចង់បាន។ ការពន្លឿនសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ជារឿយៗមានអាទិភាពខ្ពស់នៅក្នុងគម្រោងអភិវឌ្ឍន៍ផ្សេងៗ ជាពិសេស គម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្នុងស្រុក និងអន្តរជាតិនានា។ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងសមភាពយេនឌ័រ ជាចំណុចផ្តោតសំខាន់របស់រាជរដ្ឋាភិបាល ដូចជាក្នុងការបង្កើត ក្រសួងកិច្ចការនារី នៅឆ្នាំ១៩៩៣ ជាដើម។ ទោះបីប្រជាជនកម្ពុជាមានអារម្មណ៍ផ្សារភ្ជាប់ខ្លួនខ្លាំងជាងតាមខ្សែខាងម្តាយ ហើយស្ត្រីដើរតួនាទីសកម្មទាំងក្នុងគ្រួសារ និងក្នុងសង្គមក្តី ក៏ស្ត្រីនៅតែជួបបញ្ហាប្រឈមក្នុងលទ្ធភាព និងឱកាសដើម្បីជះឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ ក្នុងសហគមន៍ និង ក្នុងមជ្ឈដ្ឋាននយោបាយ (Baudinet 2018, MOWA 2014,Thon 2017) ។

អត្ថបទនេះសង្ខេបលទ្ធផលការវិភាគយេនឌ័រ (Un, Saphon and Sok 2019) នៃអង្កេតតំណាងឲ្យទូទាំងប្រទេសដែលរៀបចំឡើងដោយផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថាន CDRI សម្រាប់ការស្រាវជ្រាវស្តីពី "យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ ទំនាក់ទំនងរវាងទាំងពីរជំនាន់ និងទស្សនៈសង្គម និងនយោបាយ" (Eng et al. 2019)។ ការសិក្សា និងការវិភាគយេនឌ័រ ជាទូទៅផ្តោតលើស្ថានភាពរបស់ស្ត្រី ឬចំណាប់អារម្មណ៍របស់ស្ត្រីលើបញ្ហាខ្លះ ដោយសន្មតថា ស្ត្រីទាំងអស់មានលក្ខណៈដូចគ្នា។ ប៉ុន្តែការវិភាគយេនឌ័រនេះមានចំណុចពិសេសមួយ គឺមិនបានចាត់ទុកស្ត្រីជាមនុស្សមួយក្រុម មានលក្ខណៈដូចគ្នាទាំងអស់នោះទេ។ ផ្ទុយទៅវិញ ការវិភាគនេះបានពិនិត្យលើ អន្តរកម្មនិងទំនាក់ទំនងហើយនិង កត្តាផ្សេងទៀតដែលនាំឲ្យមាន ភាពខុសគ្នារវាងស្ត្រីនឹងស្ត្រី និងភាពខុសគ្នារវាងស្ត្រីនឹងបុរស ដោយធ្វើការបំបែកទិន្នន័យលើលក្ខណៈសម្បត្តិផ្សេងៗ ដើម្បីស្វែងយល់ថា តើស្ត្រីដែលមានលក្ខណៈសម្បត្តិខុសៗគ្នា គាត់មានចំណាប់អារម្មណ៍ខុសគ្នាលើបញ្ហាមួយចំនួនដែរ ឬយ៉ាងណា?

## ការសិក្សា៖ វិធីសាស្ត្រ និងទិន្នន័យ

អង្កេតបានធ្វើឡើងពីខែតុលា ២០១៧ ដល់ មករា ២០១៨ ដោយមានការធ្វើសម្ភាសន៍ជាមួយពលរដ្ឋកម្ពុជាចំនួន ១.៦០០នាក់ ក្នុង ១០១ភូមិ (៧២% នៅជនបទ និង ២៩% នៅទីក្រុង) ក្នុងខេត្តចំនួន ៥ (កំពត បាត់ដំបង ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម) និងរាជធានីភ្នំពេញ។ ក្នុងក្របខ័ណ្ឌសំណាក មានអ្នកឆ្លើយសម្ភាសន៍ ៩៥៧នាក់ជាស្ត្រី និង ៦៤៣នាក់ជាបុរស ដែលចែកចេញជាពីរក្រុមគឺ ជនវ័យក្មេងឬយុវជន (អាយុ ១៦-៣០ឆ្នាំ) និង មនុស្សជំនាន់មុន (អាយុលើស ៣០ឆ្នាំ) ដូច្នេះ ក្នុងសំណាកសរុបមាន ២៤,៩% ជាយុវជន និង ៧៥,១% ជាមនុស្សជំនាន់មុន ។ កម្រងសំណួរអង្កេត មាន ១០១សំណួរចែកចេញជា ៦ផ្នែក ដែលជាប់ទាក់ទងនឹង ប្រជាសាស្ត្រ អត្តសញ្ញាណ និងសីលធម៌ ទំនុកចិត្តនិងការគោរព ការរំពឹងទុកទៅអនាគត ការចូលរួមផ្នែកនយោបាយ និង ប្រព័ន្ធផ្សព្វផ្សាយ។

ការវិភាគយេនឌ័រ (Un, Saphon and Sok 2019) បានយកចម្លើយក្នុងអង្កេត មកធ្វើជាប្រភពទិន្នន័យចម្បងតែមួយគត់ ដោយបែងចែកតាមប្រធានបទធំៗចំនួនបួន៖ គ្រួសារ ឥរិយាបថចំពោះសហគមន៍ ចំណេះដឹងនិងឥរិយាបថផ្នែកនយោបាយ និង ការរំពឹងទុកទៅអនាគត។ ចម្លើយតាមប្រធានបទនីមួយៗបានយកមកផ្តុំតាមប្រធានបទតូចៗជាច្រើន និងដាក់លេខកូដតាមលក្ខណៈសម្បត្តិ ៧យ៉ាង (តារាង ១ និង ២)។

---

អត្ថបទនេះរៀបរៀងដោយ បណ្ឌិត អ៊ុន លាង ព្រឹទ្ធបុរស មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ សោម៉ូលីរស្មី សោភ័ណ អ្នកសម្របសម្រួលកម្មវិធី បរិញ្ញាបត្រជាន់ខ្ពស់ ខាងទស្សនវិជ្ជា និង សុខ សេរី អនុប្រធានការិយាល័យស្រាវជ្រាវ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សូមយោងអត្ថបទនេះថា៖ UN Leang, Somolireasmey Saphon and Serey Sok . 2019. “Gender Analysis of Survey on Cambodia’s Young and Older Generation: Family, Community, Political Knowledge and Attitudes, and Future Expectations.” *Cambodia Development Review* 22 (4): 10-14. Phnom Penh: CDRI.

តារាង១៖ ប្រធានបទចម្បងៗ និងប្រធានបទតូចៗ

| ប្រធានបទចម្បងៗ | ប្រធានបទតូចៗ |
|---|---|
| គ្រួសារ | គម្លាតរវាងជំនាន់មនុស្ស<br>ការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ<br>ការធ្វើសេចក្តីសម្រេចចិត្តអំពីការរៀបការ |
| ឥរិយាបថចំពោះសហគមន៍ | ទំនុកចិត្តផ្នែកសង្គមនិងស្ថាប័ន<br>ការគិតគូរពីប្រទេសជាតិ<br>ការចូលរួមក្នុងសហគមន៍ |
| ចំណេះដឹង និងឥរិយាបថផ្នែកនយោបាយ | ការយល់ឃើញផ្នែកយេនឌ័រលើភាពជាអ្នកដឹកនាំ<br>ការចូលរួមផ្នែកសង្គមនិងនយោបាយ<br>ការបារម្ភពីបញ្ហា និងសេវាផ្នែកសង្គម |
| ការរំពឹងទុកទៅអនាគត | ទិសដៅរបស់ប្រទេសជាតិ<br>ការរំពឹងទុកផ្ទាល់ខ្លួន |

តារាង២៖ ការដាក់លេខកូដទិន្នន័យ

| លក្ខណសម្បត្តិ | រង្វាស់ |
|---|---|
| អាយុ | យុវជនឬជនវ័យក្មេង (អាយុ ១៦-៣០ឆ្នាំ)<br>មនុស្សជំនាន់មុន (អាយុលើស ៣០ឆ្នាំ) |
| កន្លែងរស់នៅ | រាជធានីភ្នំពេញ<br>មិនមែនរាជធានីភ្នំពេញ |
| កម្រិតអប់រំសម្រេចបាន * | ការអប់រំកម្រិតមូលដ្ឋានឬទាបជាង<br>ការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន |
| ស្ថានភាពរៀបការ | នៅលីវ<br>មិនមែននៅលីវ (រៀបការរួច, រួមរស់ជាមួយគ្នា) |
| ប្រភេទការងារ | ការងារមានប្រាក់ឈ្នួល<br>ការងារគ្មានប្រាក់ឈ្នួល |
| ភាពចល័ត | ពលករចំណាកស្រុក<br>មិនមែនពលករចំណាកស្រុក |
| លទ្ធភាពប្រើប្រាស់អ៊ីនធើណិត | អ្នកប្រើប្រាស់អ៊ីនធើណិត<br>មិនមែនអ្នកប្រើប្រាស់អ៊ីនធើណិត |

កំណត់សំគាល់៖ *បានជ្រើសរើសយកប្រភេទទាំងនេះ ព្រោះរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា ការអប់រំកម្រិតមូលដ្ឋាន គឺ ការបានចូលរៀនក្នុងសាលាយ៉ាងហោចណាស់ ៩ឆ្នាំ ប៉ុន្តែជាមធ្យម(mean)ការចូលរៀនក្នុងសាលានៅកម្ពុជាមានកម្រិតទាបត្រឹម ៤,៨ឆ្នាំ នៅឆ្នាំ២០១៧ (hdr.undp.org/sites/all/them es/hdr_theme/country-notes/KHM.pdf).

ការផ្ទុំផ្គងទិន្នន័យលើលក្ខណសម្បត្តិទាំង ៧ ដែលបានជ្រើសយក បានផ្តល់នូវតារាងច្រើនណាស់ ដូច្នេះអ្នកស្រាវជ្រាវបានប្រើលក្ខណវិនិច្ឆ័យដូចខាងក្រោម ដើម្បីស្វែងរកលទ្ធផលសំខាន់ៗ៖

- សំណួរអង្កេតជាប់ពាក់ព័ន្ធល្អនឹងប្រធានបទទាំងបួនដែលបានជ្រើសយកសម្រាប់ការសិក្សា
- ភាពខុសគ្នាជាភាគរយ រវាងចម្លើយនានាលើលក្ខណសម្បត្តិនីមួយៗ។ ភាពខុសគ្នាត្រូវបានបញ្ជាក់តាមស្ថិតិ (បើសិនមានទិន្នន័យ) បើពុំនោះទេ ភាពខុសគ្នា ១០% ត្រូវបានយកមកប្រើជាកម្រិតគោល
- សំណួរដដែលឬស្រដៀងគ្នាត្រូវបាន ស្ថាប័នរដ្ឋ អ្នកស្រាវជ្រាវអង្កេតសម្រាប់ការស្រាវជ្រាវ និងការសិក្សានានា លើកមកពិភាក្សា និងផ្តល់អាទិភាព។

## លទ្ធផលរកឃើញ

លទ្ធផលបង្ហាញថា លក្ខណសម្បត្តិនានាដែលបានជ្រើសយកមកវិភាគ ធ្វើឲ្យគេមានអារម្មណ៍ថា ស្ត្រីជាមនុស្សមានប្រភេទខុសៗគ្នា ហើយលក្ខណសម្បត្តិទាំងនេះជះឥទ្ធិពលខ្លាំងដល់ការចូលរួម និងការយល់ដឹងផ្នែកសង្គម និងផ្នែកនយោបាយរបស់ស្ត្រី។ លទ្ធផលរកឃើញនេះ មានការពាក់ព័ន្ធសំខាន់សម្រាប់គោលនយោបាយ និងរបៀបរបបអនុវត្តផ្នែកយេនឌ័រ ក៏ដូចជាការស្រាវជ្រាវទៅអនាគត ពីព្រោះការព្យាយាមផ្តល់សិទ្ធិអំណាច និងលើកកម្ពស់សមភាពនិងសមធម៌ផ្នែកយេនឌ័រដល់ស្ត្រី ដោយចាត់ទុកស្ត្រីជាមនុស្សមួយក្រុមដូចគ្នាទាំងអស់នោះ ទំនងមិនអាចបានផលដូចការរំពឹងទុកឡើយ។

### *គ្រួសារ*

*គម្លាតរវាងជំនាន់មនុស្ស៖* ការប្រែប្រួលផ្នែកប្រជាសាស្ត្រ ដោយសារការស្ទុះឡើងជាខ្លាំងនៃកំណើតទារក (baby boom) ក្រោយពេលរបបខ្មែរក្រហមបានដួលរលំ គួបផ្សំនឹង ការល្អប្រសើរឡើងក្នុងការអប់រំ ក្នុងលទ្ធភាពបានប្រើប្រព័ន្ធផ្សព្វផ្សាយ ក្នុងរបៀបរស់នៅមានវប្បធម៌ចម្រុះនៅទីក្រុង គឺបាននាំឲ្យមានគម្លាតរវាងជំនាន់មនុស្ស។ ក្នុងនេះអ្នកឆ្លើយសម្ភាសន៍ភាគច្រើនបានទទួលស្គាល់ថា ជំនាន់គាត់ខុសប្លែកជាខ្លាំងពីជំនាន់ផ្សេងទៀត និងមានតែជាង ៥០% បន្តិចប៉ុណ្ណោះដែលយល់ស្របថា គេអាចទទួលយកបាន បើសិនយុវជនមិនឯកភាពជាមួយឪពុកម្តាយ។ សម្រាប់អ្នកឆ្លើយសម្ភាសន៍ជាស្ត្រី គេរកឃើញថា អ្នករស់នៅរាជធានីភ្នំពេញ អ្នកមានការសិក្សាអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និងអ្នកប្រើអ៊ីនធើណិត តែងមានចំណាប់អារម្មណ៍ខុសប្លែកពីគេ។

*ការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ៖* គម្លាតរវាងជំនាន់មនុស្សមិនគ្រាន់តែប៉ះពាល់ដល់បញ្ហាថា អ្នកណាត្រូវធ្វើសេចក្តីសម្រេចចិត្តនោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ បញ្ហាអ្វីត្រូវធ្វើសេចក្តីសម្រេចចិត្ត និងហេតុអ្វីត្រូវធ្វើសេចក្តីសម្រេចចិត្ត ផងដែរ។ ថ្វីបើឪពុកម្តាយនៅតែមានភារកិច្ចធ្វើការសម្រេចចិត្ត ប៉ុន្តែយុវជនកាន់តែមានអារម្មណ៍ថា ខ្លួនឯងគួរមានទំនួលខុសត្រូវធ្វើការសម្រេចចិត្តលើដំណើរជីវិតរបស់ខ្លួន ដូចជាលើ ការអប់រំ ការងារ និង ការរៀបការ ជាដើម។ ឧទាហរណ៍ ឪពុកម្តាយនៅតែសម្រេចអារកាត់ច្រើនលើការអប់រំ ប៉ុន្តែតែងបានចូលរួមសម្រេចចិត្តតិចជាងក្នុងការជ្រើសរើសការងារសម្រាប់កូន។ សម្រាប់អ្នកឆ្លើយសម្ភាសន៍ជាស្ត្រី គេបានពិនិត្យឃើញនូវ ចំនួនភាគរយយ៉ាងខ្ពស់នៃអ្នករស់នៅរាជធានីភ្នំពេញ អ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និង អ្នកប្រើអ៊ីនធើណិត ដែលយល់ថា យុវជនគួរមានសិទ្ធិអំណាចធ្វើការសម្រេចចិត្តដោយខ្លួនឯង។

*ការរៀបការ៖* សង្គមកម្ពុជាឲ្យតម្លៃខ្ពស់ដល់មង្គលការ ព្រោះវាជាជំហានគេអាចទទួលយកបាន និងគោរពទទួលស្គាល់ ដើម្បីកសាងគ្រួសារ និងក្លាយជាឪពុកម្តាយគេ។ ការរួមរស់ជាមួយគ្នាមុនពេលរៀបការ ពុំមានការឲ្យតម្លៃ ឬទទួលយកពីមហាជនទេ។ ជាក់ស្តែង ប្រមាណ ៨០% នៃស្ត្រីឆ្លើយសម្ភាសន៍បាននិយាយថា

គូគ្រងមិនគួររួមរស់ជាមួយគ្នា មុនពេលរៀបការទេ ហើយសឹងគ្រប់គ្នាយល់ថា មង្គលការ និងការកសាងគ្រួសារមានសារៈសំខាន់ខ្លាំង ចំណែកឯ អ្នកឆ្លើយសម្ភាសន៍ជាងពាក់កណ្ដាល យល់ថា មង្គលការ និងការកសាងគ្រួសារមានសារៈសំខាន់ក្រៃលែង។ យ៉ាងនេះមិនមែនមានន័យថា គ្មានស្ត្រីជំទាស់នឹងទំនៀមទម្លាប់ប្រពៃណីនោះទេ ព្រោះមានស្ត្រីខ្លះឆ្លើយសម្ភាសន៍យល់ស្របនឹងការរួមរស់ជាមួយគ្នាមុនពេលរៀបការ ក្នុងនេះ មាន អ្នករស់នៅរាជធានីភ្នំពេញ ១៨,៧% អ្នកមិនរស់នៅរាជធានីភ្នំពេញ ១១,៥% ស្ត្រីវ័យចំណាស់ ១៣,៨% និង ស្ត្រីវ័យក្មេង ៩,៨% ។

## ឥរិយាបថចំពោះសហគមន៍

*ទំនុកចិត្តលើសង្គម៖* ទំនុកចិត្តលើសង្គម មានសារៈសំខាន់ដល់សេដ្ឋកិច្ចសង្គមរបស់ប្រទេសជាតិ (ឧទាហរណ៍ កំណើនសេដ្ឋកិច្ច និងការពេញចិត្តនឹងជីវភាពរស់នៅ) គឺដូចគ្នានឹងវិនិយោគលើទ្រព្យមូលធន ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍជំនាញដែរ។ អង្កេតវាស់វែងបរិយាកាសអាស៊ី(Asia Barometer Survey)ឆ្នាំ២០០៣-០៦ ក្នុង ២៩ប្រទេស បង្ហាញថា កម្ពុជាមានទំនុកចិត្តលើសង្គមកម្រិតទាបជាងគេ (Tokuda, Fujii and Inoguch 2010) ដែលអាចបណ្ដាលមកពី សង្គ្រាមអូសបន្លាយជិតបីទសវត្សរ៍ របបគ្រប់គ្រងផ្ដាច់ការខ្មែរក្រហម (Zucker 2013; Scheer 2017) និងផលប៉ះពាល់ពីការផ្ដល់សេវាដែលមានអំពើពុករលួយ ក្នុងអំឡុងនៃការកសាងប្រទេសឡើងវិញក្រោយបញ្ចប់សង្គ្រាម (Baker and Milne 2019)។ ប៉ុន្តែគួរឲ្យរីករាយណាស់ដែល លទ្ធផលអង្កេតចុះក្នុង តារាង ៣ បង្ហាញថា ប្រជាជនមានទំនុកចិត្តខ្ពស់បង្គួរ ឬខ្ពស់ ទៅលើសាលារៀន មន្ទីរពេទ្យ ស្ថាប័នក្នុងមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ ប៉ូលីសនិងតុលាការ និង អ្នកនយោបាយ ទោះបីក្នុងកម្រិតខុសៗគ្នាក្ដី។ គួរកត់សំគាល់ថា មានអ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ដែលជ្រើសយកប្រយោគថា "ខ្ញុំមិនទុកចិត្តស្ថាប័ន ឬជនណាមួយទេ" ។

តារាង៣៖ តើអ្នកទុកចិត្តលើស្ថាប័នណា ឬអ្នកណាខ្លាំងជាងគេ (%) (N=1600)

| | បុរស | ស្ត្រី |
|---|---|---|
| មន្ទីរពេទ្យ/សាលារៀន | 89.4 | 92.3 |
| ស្ថាប័នក្នុងមូលដ្ឋាន | 87.5 | 88.7 |
| ប្រព័ន្ធផ្សព្វផ្សាយ | 77.5 | 75.6 |
| ប៉ូលីស/តុលាការ | 71.4 | 78.3 |
| អ្នកនយោបាយ | 65.7 | 65.6 |
| ខ្ញុំមិនទុកចិត្តលើ ស្ថាប័ន/អ្នកណាទេ | 3.8 | 2.8 |

ទោះបីមានជោគជ័យគួរឲ្យសរសើរក្ដី កម្ពុជានៅតែជាប្រទេសកំពុងអភិវឌ្ឍ និងពឹងផ្អែកលើជំនួយគាំទ្រពីស្ថាប័នសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិនានា។ ប៉ុន្តែដូចអ្នកសង្កេតការណ៍ជាច្រើននាក់បានលើកឡើងដែរ វត្តមានស្ថាប័នទាំងនេះមិនមែនគ្មានបញ្ហាចោទអ្វីសោះនោះទេ (Domashneva 2013)។ មានស្ត្រីអ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ ក្នុងនោះមានទាំងអ្នកមានការអប់រំកម្រិតខ្ពស់ និងអ្នករស់នៅរាជធានីភ្នំពេញផង ដែលមានអារម្មណ៍ថា អាចទុកចិត្តទាំងស្រុងទៅលើអ្នកធ្វើការផ្នែកអភិវឌ្ឍន៍នៅក្នុងសហគមន៍របស់ខ្លួន។ គួរកត់សំគាល់ថា មានស្ត្រីច្រើននាក់និយាយថា គាត់ "ទុកចិត្តខ្លះ/មិនទុកចិត្តខ្លះ" លើអ្នកធ្វើការផ្នែកអភិវឌ្ឍន៍។ បញ្ហានេះជាក្ដីបារម្ភមួយ ព្រោះកម្ពុជាមានចំនួន NGOs សកម្មតិតក្នុងមនុស្សម្នាក់ ច្រើនជាងគេលំដាប់ទី២ក្នុងពិភពលោក (Domashneva 2013)។

*ការគិតគូរពីប្រទេសជាតិ និងការចូលរួមក្នុងសហគមន៍៖* ជាងពាក់កណ្ដាលនៃស្ត្រីអ្នកឆ្លើយសម្ភាសន៍និយាយថា គាត់គិតគូរពីសហគមន៍គាត់ និងប្រទេសជាតិ។ ការវិភាគតាមលក្ខណសម្បត្តិផ្សេងៗបង្ហាញថា ក្នុងចំណោមអ្នកនិយាយថា ខ្លួនគិតគូរពីប្រទេសជាតិ ស្ត្រីវ័យចំណាស់ (៥៩,៣%) មានច្រើនជាងស្ត្រីវ័យក្មេង (៤៨,៦%) ហើយ អ្នករស់នៅតំបន់ជនបទ (៥៨,៤%) មានច្រើនជាងអ្នករស់នៅរាជធានីភ្នំពេញ (៤៧,៦%)។ ប៉ុន្តែការគិតគូរនេះ មិនមែនសុទ្ធតែស្ដែងចេញជាការចូលរួមសកម្មក្នុងសហគមន៍ឬសង្គមនោះទេ ជាពិសេស ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍រស់នៅក្រុងភ្នំពេញ អ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និងអ្នកមិនប្រើអ៊ីនធើណិត។ តាមពិត ការចូលរួមមានលក្ខណៈអកម្មភាគច្រើន។ ជាក់ស្ដែង ស្ត្រីភាគច្រើនដែលបានចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗនៅតាមមូលដ្ឋាន មិនបាននិយាយ ឬលើកសំណួរអ្វីទេ ទោះបីគាត់អះអាងថា គាត់មិនខ្លាចបញ្ចេញមតិ ឬលើកសំណួរក្ដី។

## ចំណេះដឹង និងឥរិយាបថផ្នែកនយោបាយ

*ការយល់ឃើញផ្នែកយេនឌ័រលើភាពជាអ្នកដឹកនាំ៖* ក្នុងសង្គមកម្ពុជា មានការលើកកម្ពស់សិទ្ធិអំណាចស្ត្រីជាខ្លាំង និងមានការផ្លាស់ប្ដូរអាកប្បកិរិយាគួរឲ្យកត់សំគាល់ ប៉ុន្តែផ្នត់គំនិត និងរបៀបរបបនិងឥរិយាបថក្នុងសង្គម នៅតែជាឧបសគ្គរាំងដល់ស្ត្រី ហើយស្ត្រីនៅតែមានអ្នកតំណាងតិច ជាពិសេស អ្នកតំណាងមានតួនាទីសម្រេចអាកាត់។ ទម្លាប់ផ្ដល់តម្លៃខ្ពស់ឲ្យទៅបុរសនៅតែចាក់ឫសយ៉ាងរឹងមាំក្នុងសង្គមកម្ពុជា ហើយអ្នកឆ្លើយសម្ភាសន៍ទាំងបុរសទាំងស្ត្រី សុទ្ធតែគោរពតាមទម្លាប់នេះដោយគិតថា វាជារបៀបរបប និងឥរិយាបថពាក់ព័ន្ធនឹងបុព្វសិទ្ធិផ្នែកយេនឌ័រ។ ក្នុងនេះបញ្ហាប្រឈមពិបាកដោះស្រាយជាងគេ អាចមិនមែនជាការរើសអើងប្រឆាំងនឹងស្ត្រីនោះទេ ប៉ុន្តែដោយសារតែ ស្ត្រីសុខចិត្តទទួលយកផ្នត់គំនិតក្នុងសង្គម ដែលចាត់ទុកខ្លួនដូចជាវត្ថុមួយបែប (Saphon 2015)។ មានអ្នកឆ្លើយសម្ភាសន៍ជាស្ត្រី ច្រើនជាងជាបុរស ដែលយល់ស្របថា បុរសធ្វើជាអ្នកដឹកនាំនយោបាយបានល្អជាងស្ត្រី និងមានច្រើននាក់ជាងដែរ ជាពិសេសក្នុងចំណោមអ្នកមានអាយុជាង ៣០ឆ្នាំ និងអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង ដែលបង្ហាញថា គាត់ភ័យខ្លាចនឹងពិភាក្សាដោយចំហពីការយល់ឃើញផ្នែកនយោបាយ។

*ភាពលំអៀងផ្នែកយេនឌ័រក្នុងការអប់រំ៖* តាមអង្កេតរបស់ CDRI (Eng at al. 2019) ៧៥% នៃអ្នកឆ្លើយសម្ភាសន៍យល់ថា ស្ត្រី និងបុរស គួរមានឱកាសស្មើគ្នាដើម្បីទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងមានប្រមាណ ៩០% ឲ្យតម្លៃខ្ពស់ដល់អ្នករៀនចប់ឧត្តមសិក្សា។ ប៉ុន្តែភាពលំអៀងផ្នែកយេនឌ័រនៅតែមាន ព្រោះមានស្ត្រីអ្នកឆ្លើយសម្ភាសន៍ច្រើននាក់ដែរដែលយល់ស្របថា ក្មេងប្រុស ប្រសើរជាងក្មេងស្រីសម្រាប់ការសិក្សានៅសាកលវិទ្យាល័យ ហើយគំនិតនេះឃើញមានច្រើនជាងគេក្នុងចំណោមស្ត្រីអាយុជាង ៣០ឆ្នាំ (៣០,៣%), អ្នកមិនរស់នៅក្នុងក្រុងភ្នំពេញ (២៨,១%) និង អ្នកមានប្ដីឬមានដៃគូរួមរស់ជាមួយ (២៨,១%)។

*ការចូលរួមក្នុងការបោះឆ្នោត៖* អ្នកឆ្លើយសម្ភាសន៍ភាគច្រើន ជាពិសេសអ្នកប្រើអ៊ីនធើណិត បានប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន។ មនុស្សជំនាន់មុនសឹងគ្រប់គ្នា (បុរស ៩៤,៣% ស្ត្រី ៩២,៤%) បានបោះឆ្នោត ក្នុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ឆ្នាំ ២០១៣ ធៀបនឹង ជនពេញវ័យនៅក្មេងមិនដល់ ៥០% ទេ ដែលបានទៅបោះឆ្នោត (បុរស ៤៣,១% ស្ត្រី ៤៤,១%)។ ក្នុងចំណោមអ្នកទៅបោះឆ្នោត មាន ៧១,៥% ជាអ្នកប្រើអ៊ីនធើណិត។ ការទៅបោះឆ្នោតច្រើនបែបនេះ បង្ហាញថា ប្រជាជនកម្ពុជាឲ្យតម្លៃដល់សិទ្ធិបោះឆ្នោតរបស់ខ្លួន ដោយយល់ឃើញថា វាជាទំនួលខុសត្រូវដ៏សំខាន់ និងជាកត្តាសំខាន់សម្រាប់របបប្រជាធិបតេយ្យ ហើយសន្លឹកឆ្នោតរបស់ខ្លួនមានប្រយោជន៍សម្រាប់ប្រទេសជាតិ។

*ចេតនាបោះឆ្នោត៖* មានអ្នកបោះឆ្នោតជាស្ត្រី (២៥,០%) ច្រើនជាងជាបុរស (១៦,៧%) និងមានស្ត្រីអាយុលើស ៣០ឆ្នាំ (៤១,៦%) ច្រើនជាខ្លាំងជាងស្ត្រីអាយុ ១៦-៣០ឆ្នាំ (២៣,៧%) ដែលបោះឆ្នោតឲ្យគណបក្សនយោបាយដដែលរហូត ក្នុងការបោះឆ្នោតថ្នាក់ជាតិ។ ចេតនានេះស៊ីគ្នានឹង បែបបទដែលអ្នកឆ្លើយសម្ភាសន៍ភាគច្រើនបោះឆ្នោត ពោលគឺ ដោយផ្អែកលើគណបក្សនយោបាយជាជាងលើគុណសម្បត្តិ ឬឥទ្ធិពលផ្សេងៗរបស់បេក្ខជន។

*ក្ដីបារម្ភពីបញ្ហា និងសេវាសង្គម៖* ក្នុងចំណោមបញ្ហា និង សេវាសង្គមជាតិទាំង ១៤មុខ (ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល សេដ្ឋកិច្ចនិងការងារ បរិស្ថាន ភាពក្រីក្រ ភាពគ្មានដីធ្លីនិងការជំពាក់បំណុល អំពើល្មើសច្បាប់និងបញ្ហាសន្តិសុខ អំពើពុករលួយ ទំនាស់រវាងគណបក្សនយោបាយ អំពើអយុត្តិធម៌ បញ្ហាព្រំដែន វិសមភាពទ្រព្យធនកាន់តែធំឡើងរវាងអ្នកក្រនឹងអ្នកមាន និង ចំណាកស្រុក) អ្នកឆ្លើយសម្ភាសន៍ទាំងស្ត្រីទាំងបុរស បានធ្វើចំណាត់ថ្នាក់ ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល សេដ្ឋកិច្ច និងការងារ និង បរិស្ថាន ជាបញ្ហាសំខាន់ៗជាងគេដែលរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ជាបន្ទាន់។

## ក្ដីរំពឹងទៅអនាគត

*ទិសដៅប្រទេសជាតិកំពុងប្រកាន់យក៖* អ្នកឆ្លើយសម្ភាសន៍ភាគច្រើនយល់ថា ប្រទេសជាតិកំពុងស្ថិតលើផ្លូវត្រូវ ដោយយោងជាសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍ដែលយល់បែបនេះ មាន ៥៩,៧% នៃអ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន និង ៧២,០% នៃអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង។ ចំណុចលេចធ្លោមួយគឺ ភាពខុសប្លែកគ្នាដោយសារការប្រើអ៊ីនធើណិត។ ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍ អ្នកយល់ឃើញថាប្រទេសជាតិកំពុងស្ថិតលើផ្លូវត្រូវ មានតែ ១៦,៧% នៃអ្នកមិនប្រើអ៊ីនធើណិត ធៀបនឹង ៥៩,០% នៃអ្នកប្រើអ៊ីនធើណិត។

*ការរំពឹងទុកទៅអនាគតរបស់បុគ្គល៖* មានស្ត្រីអ្នកឆ្លើយសម្ភាសន៍ក្នុងចំនួនភាគរយខ្ពស់គួរឲ្យកត់សំគាល់ ដែលបារម្ភថា ផ្នត់គំនិតផ្នែកយេនឌ័រ ជាឧបសគ្គរាំងដល់ជោគជ័យក្នុងអាជីពរបស់ខ្លួន។ ជាក់ស្ដែង ក្នុងចំណោមស្ត្រីអ្នកឆ្លើយសម្ភាសន៍ គឺក្រុមស្ត្រីវ័យចំណាស់ អ្នកមិនរស់នៅក្នុងក្រុងភ្នំពេញ និងអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង តែងគិតឃើញធ្ងន់ធ្ងរជាង ស្ត្រីវ័យក្មេង និងអ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន ថា ផ្នត់គំនិតផ្នែកយេនឌ័រជាឧបសគ្គរាំងដល់ជោគជ័យរបស់ខ្លួន។

## សេចក្ដីសន្និដ្ឋាន

កម្ពុជា នៅមាន ចំណុចជាច្រើនដែលអាចកែលំអថែមទៀត ក្នុងការផ្ដល់សិទ្ធិអំណាចឲ្យស្ត្រី និង ក្នុងសមភាពផ្នែកយេនឌ័រ ទោះបីជា ទិដ្ឋភាពជាច្រើននៃជីវិតរស់នៅជាក់ស្ដែងរបស់ស្ត្រីបានល្អប្រសើរឡើងគួរឲ្យកត់សំគាល់ក្ដី។ ការល្អប្រសើរនេះមិនមែនសម្រាប់តែស្ត្រីខ្លួនឯងនោះទេ ប៉ុន្តែក៏សម្រាប់ការចូលរួមក្នុងសង្គមផងដែរ។ រហូតមកដល់ពេលថ្មីៗនេះ ការសិក្សាវិភាគពីយេនឌ័រនានា បានប្រៀបធៀបស្ថានភាពស្ត្រីពីមួយឆ្នាំទៅមួយឆ្នាំ និងបានប្រៀបធៀបជាមួយស្ថានភាពរបស់បុរស ហើយជាទូទៅតែងចាត់ទុកស្ត្រីជាមនុស្សមួយក្រុមដូចគ្នាទាំងអស់។ លទ្ធផលរកឃើញបង្ហាញថា លក្ខណៈ និងបទពិសោធន៍ខុសប្លែកគ្នា ជះឥទ្ធិពលទៅលើចំណាប់អារម្មណ៍ និងការចូលរួមរបស់ស្ត្រីក្នុងបញ្ហាសង្គម-នយោបាយផ្សេងៗ។ ដូច្នេះ ការព្យាយាមណាមួយដើម្បីផ្ដល់សិទ្ធិអំណាចដល់ស្ត្រី និងលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ ប៉ុន្តែដោយចាត់ទុកស្ត្រីជាមនុស្សមួយក្រុមដូចគ្នាទាំងអស់ គឺពិតជាមិនអាចបានផលដូចការរំពឹងទុកទេ។

សម្រាប់លក្ខណៈសម្បត្តិទាំង ៧ ដែលបានជ្រើសរើសសម្រាប់ការសិក្សា ក្រុមស្រាវជ្រាវសន្និដ្ឋានថា កត្តា អាយុ កន្លែងស្នាក់នៅ កម្រិតអប់រំ និង ការប្រើអ៊ីនធើណិត មានឥទ្ធិពលគួរឲ្យកត់សំគាល់ទៅលើ ចំណាប់អារម្មណ៍ និងការចូលរួមរបស់ស្ត្រីក្នុងសង្គម-នយោបាយ។ ខាងក្រោមនេះ ជាសេចក្ដីសង្ខេបនៃលទ្ធផលរកឃើញ និងបញ្ហាកំពុងផុសឡើង ដែលគួរទទួលបានការយកចិត្តទុកដាក់ខ្លាំងថែមទៀត ពីបណ្ដាស្ថាប័នមានបេសកកម្មលើកកម្ពស់ការផ្ដល់សិទ្ធិអំណាចដល់ស្ត្រី និងសមភាព និងសមធម៌ផ្នែកយេនឌ័រ។

- គ្រួសារ
  - ជនវ័យក្មេង កាន់តែត្រូវបានអនុញ្ញាតឲ្យទទួលខុសត្រូវធ្វើការសម្រេចចិត្តលើដំណើរជីវិតរបស់ខ្លួន។ *ស្ត្រីវ័យក្មេង ជាអ្នកមានការអប់រំខ្ពស់ជាងកម្រិតមូលដ្ឋាន ជាអ្នករស់នៅ*

*រាជធានីភ្នំពេញ និងជាអ្នកប្រើអ៊ិនធើណិត ទំនងមានការយល់ស្របតិច ជាមួយ ប្រពៃណីក្នុងសង្គមកម្ពុជា និងរបៀបរបបរស់នៅ និងការគិតគូរបែបអភិរក្ស បើធៀបនឹង ស្ត្រីវ័យក្មេងមានការអប់រំកម្រិតមូលដ្ឋាន ឬទាបជាង ស្ត្រីរស់នៅរាជធានីភ្នំពេញ និងស្ត្រីមិនប្រើអ៊ិនធើណិត។*

- ឥរិយាបថចំពោះសហគមន៍
  - បញ្ហាទំនុកចិត្តរបស់ប្រជាពលរដ្ឋទៅលើស្ថាប័នជាតិ និងមន្ត្រីរាជការ អាចឡើងដល់កម្រិតមុនពេលមានសង្គ្រាម ឬយ៉ាងណា គេមិនទាន់ដឹងនៅឡើយទេ ប៉ុន្តែលទ្ធផលអង្កេតបានបង្ហាញសញ្ញាវិជ្ជមានខ្លះ។ ប្រជាជនយល់ថា មន្ទីរពេទ្យ សាលារៀន ជាស្ថាប័នគួរឲ្យទុកចិត្តជាងគេ រីឯស្ថាប័នក្នុងមូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ ប៉ូលីស/តុលាការ និង អ្នកនយោបាយ គឺអាចទុកចិត្តបានបង្គួរ។ ចំណុចសំខាន់គួរកត់សំគាល់ គឺមាន *អ្នកឆ្លើយសម្ភាសន៍តិចនាក់ណាស់ដែលបញ្ជាក់ថា មិនមានទំនុកចិត្តលើស្ថាប័នឬជនណាមួយដូចខាងលើ។*
  - ប្រមាណជិតពាក់កណ្ដាលនៃ ស្ត្រីអ្នកឆ្លើយសម្ភាសន៍ ទុកចិត្តខ្លះ មិនទុកចិត្តខ្លះ ទៅលើអ្នកធ្វើការផ្នែកអភិវឌ្ឍន៍។ *ចំណុចនេះគួរឲ្យបារម្ភដែរ ព្រោះនៅកម្ពុជា មានចំនួន NGOs សកម្មគិតក្នុងមនុស្សម្នាក់ ច្រើនជាងគេលំដាប់ទី២ ក្នុងពិភពលោក។*
  - ស្ត្រីអ្នកឆ្លើយសម្ភាសន៍ភាគច្រើន ឬមួយគិតគូរ ឬមួយគិតគូរខ្លះមិនគិតគូរខ្លះ ពីប្រទេសជាតិខ្លួន ហើយការគិតគូរនេះឃើញមានច្រើនជាងគេក្នុងចំណោម ស្ត្រីវ័យចំណាស់ (ធៀបនឹងស្ត្រីវ័យក្មេង) និងអ្នកមិនរស់នៅរាជធានីភ្នំពេញ (ធៀបនឹងអ្នករស់នៅរាជធានីភ្នំពេញ)។ ចំណុចនេះគួរយកចិត្តទុកដាក់ដែរ *ព្រោះនៅកម្ពុជា យុវជនតំណាងឲ្យប្រមាណ ៦០% នៃប្រជាជនសរុប ហើយនគរូបនីយកម្មមានល្បឿនយ៉ាងលឿន។*
  - ការគិតគូរពីប្រទេសជាតិ មិនមែនសុទ្ធតែស្ដែងចេញជាការចូលរួមសកម្មក្នុងសហគមន៍នោះទេ។ សូម្បីក្នុងចំណោមអ្នកចូលរួមការប្រជុំក្នុងមូលដ្ឋានដែលអះអាងថា គាត់មិនខ្លាចបញ្ចេញមតិក្នុងពេលចូលរួមក្ដី ក៏ភាគច្រើនមិនដែលមានលើកជាសំណួរអ្វីទេក្នុងពេលចូលរួម។ ការសិក្សាថែមទៀត ដើម្បីពិនិត្យពីការរារែករបស់ប្រជាជនក្នុងការបញ្ចេញមតិនៅពេលប្រជុំជាសាធារណៈ អាចជួយពង្រឹងគុណភាពនៃការចូលរួមបំពេញភារកិច្ចជាពលរដ្ឋ។
- ចំណេះដឹង និងឥរិយាបថផ្នែកនយោបាយ
  - ទោះបីមានកិច្ចប្រឹងប្រែង ដើម្បីផ្ដល់សិទ្ធិអំណាចដល់ស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រក្ដី ក៏នៅតែមានការយល់ឃើញថា បុរសធ្វើជាអ្នកដឹកនាំបានល្អជាងស្ត្រី។ ផ្នត់គំនិតនេះនៅតែឃើញមានជាទូទៅ ក្នុងចំណោមស្ត្រី ជាពិសេស ស្ត្រីវ័យចំណាស់ ស្ត្រីមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង និងស្ត្រីមិនប្រើអ៊ិនធើណិត។ ស្ត្រីមានច្រើនជាងបុរសដែលយល់ថា យេនឌ័រជាឧបសគ្គរាំងជោគជ័យរបស់ខ្លួន ជាពិសេស ស្ត្រីវ័យចំណាស់ អ្នកមិនរស់នៅរាជធានីភ្នំពេញ និងអ្នកមានការអប់រំកម្រិតមូលដ្ឋានឬទាបជាង។ ការដោះស្រាយបញ្ហាសមភាពយេនឌ័រ មិនមែនគ្រាន់តែជាការដោះស្រាយផ្នត់គំនិតរបស់បុរស ស្ដីពី ឋានៈរបស់ស្ត្រី ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការដោះស្រាយចំណាប់អារម្មណ៍របស់ស្ត្រីផ្ទាល់ អំពីតម្លៃ និងតួនាទីរបស់ខ្លួននៅក្នុងសង្គមផងដែរ។ ស្ត្រីមិនគ្រាន់តែទទួលរងការគាបសង្កត់ពីបុរសប៉ុណ្ណោះទេ ប៉ុន្តែក៏មានការគាបសង្កត់ដោយខ្លួនឯងផ្ទាល់ ឲ្យនៅជាក្រុមក្រោមបង្គាប់គេ ហើយគំនិតនេះនៅតែជាបញ្ហាស្នូលមួយក្នុងសង្គមកម្ពុជា។
  - អ្នកឆ្លើយសម្ភាសន៍ភាគច្រើន បានប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួន និងបានដឹងពីសារៈសំខាន់នៃសន្លឹកឆ្នោតខ្លួនសម្រាប់អនាគតប្រទេសជាតិ។ ពួកគាត់យល់ថា រាជរដ្ឋាភិបាលអាចដោះស្រាយក្ដីបារម្ភរបស់គាត់អំពីសេវា និងបញ្ហាសង្គមជាតិផ្សេងៗ ហើយក្នុងនោះសំខាន់បំផុត គឺហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខាភិបាល សេដ្ឋកិច្ចនិងការងារ និងបរិស្ថាន។
- ការរំពឹងទុកទៅអនាគត
  - អ្នកឆ្លើយសម្ភាសន៍ភាគច្រើនយល់ថា ប្រទេសជាតិកំពុងស្ថិតលើផ្លូវត្រូវ ទោះបីជាមានស្ត្រីអ្នកមិនប្រើអ៊ិនធើណិតតិចនាក់ណាស់ដែលយល់ឃើញដូច្នេះក្ដី។ ចំណុចនេះបង្ហាញពីតម្រូវការបង្កើនចំណេះដឹងពីអ៊ិនធើណិត ព្រមទាំងបំផុសចំណាប់អារម្មណ៍ និងចែករំលែកព័ត៌មាន អំពីសេវា និងបញ្ហាសង្គមមួយចំនួន។

## ឯកសារយោង


Baker, Jacqui, and Sarah Milne. 2019. "Cambodia's Anticorruption Regime 2008-2018: A Critical Political Economy Approach." www.u4.no/publications/cambodias-anti-corruption-regime-2008-2018-a-critical-political-economy-approach.pdf.

Baudinet, Marc. 2018. *Cambodia in the Twenty-First Century: A Short Social Study*. Phnom Penh: Marc Baudinet.

Domashneva, Helena. 2013. "NGOs in Cambodia: It's Complicated." *The Diplomat*, 3 Dec 2013. https://thediplomat.com/2013/12/ngos-in-cambodia-its-complicated/.

Eng Netra, Ang Len, So Hengvotey, Hav Echoing, Chhom Heavy. 2019. *Cambodia's Young and Older Generation: Views on Generational Relations and Key Social and Political Issues*. CDRI Working Paper Series No. 116. Phnom Penh: Cambodia Development Resource Institute.

MOWA (Ministry of Women's Affairs). 2014. Neary Rattanak IV: Strategic plan (2014 – 2018) for Gender Equality and the Empowerment of Women in Cambodia. Phnom Penh.

Saphon Somolireasmey. 2015. "Women, Invisibility and Culture in Cambodian Society." PhD dissertation, University of Oviedo, Spain.

Scheer, Catherine. 2017. "New Life in an Expanding Market Economy: Moral Issues among Cambodia's Highland Protestants." In *"New Religiosities, Modern Capitalism, and Moral Complexities in Southeast Asia"*, edited by Juliette Koning and Gwenaël Njoto-Feillard, 65–88. Singapore: Palgrave.

Thon Theary. 2017. *A Proper Woman*. Phnom Penh: Self-published.

Tokuda, Yasuharu, Seiji Fujii and Takashi Inoguchi. 2010. "Individual and Country-Level Effects of Social Trust on Happiness: The Asia Barometer Survey." *Journal of Applied Social Psychology* 40 (10): 2574–2593.

Un Leang, Saphon Somolireasmey and Sok Serey. 2019. *Gender Analysis of Survey on Cambodia's Young and Older Generation: Family, Community, Political Knowledge and Attitudes, and Future Expectations.* Working Paper Series XXX. Phnom Penh: CDRI.

Zucker, Eve Monique. 2013. *Forest of Struggle: Moralities of Remembrance in Upland Cambodia*. Honolulu: Hawaii University Press.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពិពណ៌នាពី សូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៣ ឆ្នាំ២០១៨។

សម្រាប់ ៥ប្រទេសអាស៊ានដែលបានជ្រើសរើស បើធៀបនឹងត្រីមាសមុន ឃើញថា មានតែប្រទេសវៀតណាមប៉ុណ្ណោះដែលមានកំណើន ផសស ពិត កើនឡើង រីឯកំណើន ផសស ពិត នៅ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី និង ថៃ បានធ្លាក់ចុះ។ ជាក់ស្តែង នៅត្រីមាសទី៣ នៅឥណ្ឌូនេស៊ី កំណើន ផសស បានចុះដល់ ៥,២% ដែលទាបជាងនៅត្រីមាសទី២ (៥,៣%) ប៉ុន្តែនៅខ្ពស់ជាងត្រីមាសទី១។ កំណើននៅម៉ាឡេស៊ី ធ្លាក់ចុះជាបន្តបន្ទាប់តាំងពីត្រីមាសទី២ ឆ្នាំ២០១៧ មក លើកលែងតែការងើបឡើងវិញមួយរយៈពេលខ្លី ដល់ ៦,២% នៅត្រីមាសបន្ទាប់ រួចធ្លាក់ចុះរហូតដល់ ៤,៤% នៅត្រីមាសទី៣ ឆ្នាំ២០១៨។ បើធៀបនឹងត្រីមាសមុនវិញ កំណើននេះថយចុះ ០,១% ប៉ុន្តែបើធៀបនឹងកាលពីមួយឆ្នាំមុន វាកើន ១,៨%។ កំណើន ផសស នៅសិង្ហបុរីក៏ថយចុះដែរ ចាប់តាំងពីត្រីមាសទី៣ ឆ្នាំ២០១៧ មក ដោយថយចុះពី ៥,២% ដល់ ២,២% នៅត្រីមាសទី៣ ឆ្នាំ២០១៨ និងថយចុះដែរបើធៀបនឹងត្រីមាសមុនដែលមានដល់ ៣,៩%។ កំណើននៅប្រទេសថៃបានថយចុះតាំងពីត្រីមាសទី១ ឆ្នាំ២០១៨ មក ដោយថយចុះពី ៤,៨% រហូតដល់ ៤,៦% នៅត្រីមាសទី២ និងដល់ ៣,៣% នៅត្រីមាសទី៣។ កំណើននៅវៀតណាមបានងើបឡើងវិញ បន្ទាប់ពីបានធ្លាក់ចុះនៅត្រីមាសទី២ ដោយកើនឡើងពី ៦,៨% នៅត្រីមាសទី២ ដល់ ៦,៩% នៅត្រីមាសទី៣។ ក្នុងចំណោមប្រទេសអាស៊ីត្រូវបានជ្រើសរើសឯទៀតៗ មានតែកូរ៉េខាងត្បូងមួយប៉ុណ្ណោះដែលសម្រេចបានកំណើន ផសស ពិត នៅត្រីមាសទី៣ ឆ្នាំ២០១៨ គឺកើនពី ២,៩% នៅត្រីមាសមុន រហូតដល់កម្រិត ៣,២%។ នៅចិន ដែលជាប្រទេសធ្លាប់មានអត្រាកំណើនលឿនជាងគេក្នុងក្រុមនេះ ក៏កំណើនបានថយចុះដល់ ៦,៥%ពោលគឺថយចុះពីកម្រិត៦,៧%នៅត្រីមាសមុន។ស្រដៀងគ្នាដែរ កំណើនសេដ្ឋកិច្ចនៅហុងកុង បានថយចុះពី ៣,៥% ដល់ ២,៩% ហើយនៅតៃវ៉ាន់ វាថយចុះពី ៣,៣% ដល់ ២,៣%។

សម្រាប់បណ្តាប្រទេសឧស្សាហកម្ម ត្រូវបានជ្រើសរើសដែលមាន តំបន់អឺរ៉ូ១២ ជប៉ុន និង សហរដ្ឋអាមេរិកនោះ គឺមានតែសហរដ្ឋអាមេរិកប៉ុណ្ណោះ ដែលសម្រេចបានកំណើន ផសស ពោលគឺកើនពី ២,៩% នៅត្រីមាសទី២ ដល់ ៣% នៅត្រីមាសទី៣ ឆ្នាំ២០១៨។ កំណើនសេដ្ឋកិច្ចជប៉ុនបានធ្លាក់ចុះតាំងពីត្រីមាសទី៤ ឆ្នាំ២០១៧ មកដល់សូន្យ នៅត្រីមាសទី៣ ឆ្នាំ២០១៨។ តំបន់អឺរ៉ូ១២ បានបាត់បង់សន្ទុះ ដោយកំណើនសេដ្ឋកិច្ចធ្លាក់ចុះពី ២,៥% នៅត្រីមាសទី៣ និង ២.៨% នៅត្រីមាសទី៤ ឆ្នាំ២០១៧ ដល់ ១,៦% នៅត្រីមាសទី៣ ឆ្នាំ២០១៨ នេះ។

## អតិផរណាក្នុងពិភពលោក

នៅចន្លោះត្រីមាសទី១ និងត្រីមាសទី៣ ឆ្នាំ២០១៨ ក្នុងចំណោមប្រទេសអាស៊ានជ្រើសរើសទាំង ៦ មានប្រទេសពីរ គឺ សិង្ហបុរី និង ម៉ាឡេស៊ី ដែលមានអតិផរណាធ្លាក់ចុះ រីឯ កម្ពុជា ឥណ្ឌូនេស៊ី ថៃ និង វៀតណាម មានអតិផរណាកើនឡើង។ នៅត្រីមាសទី៣ ឆ្នាំ២០១៨ វៀតណាមមានអតិផរណាឡើងដល់ ៤,៥% ដែលជាអត្រាអតិផរណាខ្ពស់ជាងគេ ហើយបន្ទាប់មកគឺឥណ្ឌូនេស៊ីដែលមានអតិផរណាកើនដល់ ៣,១% និងនៅកម្ពុជាដែលកើនដល់ ២,៥%។ ម៉ាឡេស៊ី និង សិង្ហបុរី មានអត្រាអតិផរណាទាប ត្រឹម ០,៤% និង ០,៧% រៀងគ្នា។

បណ្តាប្រទេសឧស្សាហកម្ម និងប្រទេសអាស៊ីត្រូវបានជ្រើសរើសទាំងអស់ មានការឡើងចុះអត្រាអតិផរណា តាំងពីត្រីមាសទី៤ ឆ្នាំ២០១៧ មក លើកលែងតែ តៃវ៉ាន់ដែលមានអត្រាអតិផរណានៅថេរត្រឹម ១,៦%។ សហរដ្ឋអាមេរិកមានអត្រាអតិផរណាខ្ពស់ជាងគេដល់ ២,៦% នៅត្រីមាសទី៣ ឆ្នាំ២០១៨ ទោះបីវាធ្លាក់ចុះបន្តិចដែរ បើធៀបនឹងត្រីមាសមុនដែលមានដល់ ២,៧%។ ចិន និងហុងកុង មានអត្រាអតិផរណាស្មើគ្នាត្រឹម ២,៣%។ កូរ៉េខាងត្បូង និងតៃវ៉ាន់ មានអត្រាអតិផរណាស្មើគ្នាត្រឹម ១,៦% ប៉ុន្តែខុសគ្នាត្រង់ តៃវ៉ាន់មានអតិផណានៅនឹង រីឯកូរ៉េខាងត្បូងមានអតិផរណាស្ទុះឡើងច្រើនដង ពោលគឺ ពី ១,២% នៅត្រីមាសទី១ និង ១,៥% នៅត្រីមាសទី២។ អតិផរណានៅតំបន់អឺរ៉ូ និងជប៉ុន បានកើនឡើងធៀបនឹងត្រីមាសមុន ដោយកើនពី ១,៧% ដល់ ២,១% នៅតំបន់អឺរ៉ូ និង ពី ០,៦% ដល់ ១,១% នៅជប៉ុន។

## អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់ក្នុងប្រទេស ត្រូវបានជ្រើសរើសមួយចំនួនមិនមានការផ្លាស់ប្តូរគួរឲ្យកត់សំគាល់ទេធៀបនឹងត្រីមាសមុនមកដល់ត្រីមាសទី៣ ឆ្នាំ២០១៨ នេះ។ ដោយឡែក ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលកម្ពុជាបានចុះថ្លៃពី៤.០៤៧,០រៀល/ដុល្លារនៅត្រីមាសទី២ ដល់ ៤.០៧៣,៧រៀល/ដុល្លារនៅត្រីមាសទី៣។ ក្នុងពេលជាមួយគ្នា ប្រាក់បាតថៃចុះថ្លៃពី ៣១,៦/ដុល្លារ ដល់ ៣៣,០បាត/ដុល្លារ ហើយប្រាក់ដុងវៀតណាមបានចុះថ្លៃដល់ ២២.៦៧៥,៧ ដុង/ដុល្លារ។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ក្នុងពេញមួយត្រីមាសទី៣ ឆ្នាំ២០១៨ ថ្លៃអង្ករ និង កៅស៊ូ បានធ្លាក់ចុះ រីឯ ថ្លៃសណ្តែកសៀង ប្រេងដូងប្រេង និងពោត បានឡើងចុះ។

ក្នុងចំណោម ទំនិញជ្រើសរើសនានា ថ្លៃកៅស៊ូបានស្ថិតនៅខ្ពស់ជាងគេក្នុងបីត្រីមាសកន្លងមក ប៉ុន្តែ បានធ្លាក់ចុះជាខ្លាំងពី

តទៅទំព័រ ១៧

អត្ថបទនេះ រៀបរៀងដោយលោក ញឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០១៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.3 | 7.4 | 7.1 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.3 | 5.8 | 5.2 | 4.8 | 5.0 | 5.0 | 5.2 | 5.1 | 5.2 | 5.1 | 5.3 | 5.2 |
| ម៉ាឡេស៊ី | 5.4 | 4.6 | 6.0 | 4.9 | 4.3 | 5.6 | 5.8 | 6.2 | 5.9 | 5.4 | 4.5 | 4.4 |
| សិង្ហបុរី | 1.3 | 3.8 | 3.0 | 2.0 | 2.0 | 2.7 | 2.9 | 5.2 | 4.3 | 4.4 | 3.9 | 2.2 |
| ថៃ | 6.7 | 2.8 | 1.6 | 2.8 | 3.2 | 3.3 | 3.7 | 4.3 | 4.0 | 4.8 | 4.6 | 3.3 |
| វៀតណាម | 5.2 | 5.4 | 5.9 | 6.6 | 6.1 | 5.1 | 6.2 | 7.5 | 7.7 | 7.4 | 6.8 | 6.9 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.7 | 7.7 | 7.3 | 7.0 | 6.7 | 6.9 | 6.9 | 6.8 | 6.8 | 6.8 | 6.7 | 6.5 |
| ហុងកុង | 2.9 | 3.0 | 2.3 | 2.3 | 1.7 | 4.3 | | 3.6 | 3.4 | 4.7 | 3.5 | 2.9 |
| កូរ៉េខាងត្បូង | 2.1 | 2.8 | 3.4 | 2.6 | 2.6 | 2.8 | 2.7 | 3.6 | 2.9 | 2.8 | 2.9 | 3.2 |
| តៃវ៉ាន់ | 1.2 | 2.2 | 3.5 | 0.6 | 1.2 | 2.6 | 2.1 | 3.1 | 3.3 | 3.0 | 3.3 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -0.5 | 0.1 | 0.7 | 1.3 | 1.6 | 1.7 | 2.1 | 2.5 | 2.8 | 2.5 | 2.2 | 1.6 |
| ជប៉ុន | 1.7 | 1.7 | 0.6 | 0.3 | 0.9 | 1.6 | 2.0 | 1.7 | 2.0 | 1.1 | 1.0 | 0.0 |
| សហរដ្ឋអាមេរិក | 2.1 | 1.8 | 2.4 | 2.3 | 1.6 | 2.1 | 2.1 | 2.3 | 2.6 | 2.8 | 2.9 | 3.0 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០១៨ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.0 | 3.9 | 1.2 | 3.0 | 4.2 | 2.7 | 2.5 | 2.3 | 2.2 | 2.7 | 2.5 |
| ឥណ្ឌូនេស៊ី | 4.3 | 7.0 | 6.4 | 6.4 | 3.5 | 3.6 | 4.1 | 3.8 | 3.4 | 3.3 | 3.2 | 3.1 |
| ម៉ាឡេស៊ី | 1.7 | 2.1 | 3.2 | 2.1 | 2.1 | 4.3 | 4.0 | 3.7 | 1.3 | 1.8 | 1.3 | 0.4 |
| សិង្ហបុរី | 4.6 | 2.3 | 1.0 | -0.5 | -0.8 | 0.7 | 0.8 | 0.5 | 0.2 | 0.2 | 0.4 | 0.7 |
| ថៃ | 3.0 | 2.2 | 1.9 | -0.9 | 0.2 | 1.1 | 0.2 | 0.5 | 0.8 | 0.6 | 1.3 | 1.5 |
| វៀតណាម | 9.3 | 6.6 | 4.8 | 0.6 | 2.7 | 5.0 | 0.8 | 2.8 | 2.7 | 2.8 | 3.8 | 4.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.7 | 2.6 | 2.0 | 1.4 | 2.0 | 1.4 | 1.4 | 1.6 | 2.2 | 2.2 | 1.8 | 2.3 |
| ហុងកុង | 4.1 | 4.0 | 4.4 | 3.1 | 2.5 | 1.0 | 2.4 | 1.8 | 2.4 | 2.4 | 2.1 | 2.3 |
| កូរ៉េខាងត្បូង | 2.1 | 1.1 | 1.3 | 0.7 | 0.8 | 2.0 | 2.0 | 2.3 | 1.2 | 1.2 | 1.5 | 1.6 |
| តៃវ៉ាន់ | 1.9 | 0.8 | 1.5 | 0.6 | 1.4 | 0.8 | 0.6 | 0.8 | 1.6 | 1.6 | 1.6 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.5 | 1.4 | 0.4 | 0.0 | 0.3 | 1.8 | 1.2 | 1.4 | 1.3 | 1.3 | 1.7 | 2.1 |
| ជប៉ុន | -0.03 | 0.4 | 2.8 | 0.9 | -0.1 | 0.2 | 0.3 | 1.1 | 1.3 | 1.3 | 0.6 | 1.1 |
| សហរដ្ឋអាមេរិក | 2.1 | 1.5 | 1.6 | 0.0 | 1.2 | 2.5 | 1.9 | 1.9 | 2.2 | 2.2 | 2.7 | 2.6 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០១៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.8 | 4027.2 | 4037.6 | 4060.4 | 4053.6 | 4015.8 | 4048.2 | 4087.8 | 4036.4 | 4012.4 | 4047.0 | 4073.7 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9363.0 | 10,419.2 | 11,850.2 | 13394.8 | 13338.3 | 13344.7 | 13312.8 | 13327.0 | 13534.8 | 13576.1 | 13944.6 | 14600.2 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.1 | 3.3 | 3.9 | 4.1 | 4.4 | 4.3 | 4.3 | 4.2 | 3.9 | 3.9 | 4.1 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.2 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.4 |
| ថៃ (បាត) | 31.1 | 30.7 | 32.5 | 34.2 | 35.3 | 35.1 | 34.3 | 33.4 | 32.9 | 31.6 | 31.9 | 33.0 |
| វៀតណាម (ដុង) | 20856.9 | 20990.3 | 21138.2 | 21917.7 | 22507.5 | 22429.1 | 22704.3 | 22732.8 | 22717.5 | 22749.5 | 22483.9 | 22675.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.3 | 6.1 | 6.2 | 6.3 | 6.6 | 6.9 | 6.9 | 6.7 | 6.6 | 6.4 | 6.4 | 6.8 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1126.6 | 1095.0 | 1053.6 | 1131.9 | 1161.0 | 1152.4 | 1129.9 | 1132.8 | 1107.0 | 1072.0 | 1079.0 | 1120.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 29.6 | 29.7 | 30.3 | 31.8 | 32.3 | 31.1 | 30.3 | 30.3 | 30.1 | 29.3 | 29.8 | 30.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.8 | 0.8 | 0.8 | 0.9 |
| ជប៉ុន (យ៉េន) | 79.8 | 97.6 | 105.9 | 121.0 | 108.8 | 113.7 | 111.1 | 110.9 | 112.9 | 108.4 | 109.1 | 111.4 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១២-២០១៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 298.4 | 259.4 | 192.9 | 169.8 | 159.2 | 160.6 | 157.7 | 148.1 | 148.8 | 163.7 | 173.3 | 157.9 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 999.3 | 856.9 | 821.4 | 622.7 | 643.6 | 773.0 | 696.3 | 706.3 | 703.0 | 673.7 | 601.0 | 612.0 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 3200.7 | 2575.3 | 1755.6 | 1392.7 | 1416.1 | 2147.7 | 1568.1 | 1551.7 | 1466.0 | 1504.0 | 1433.3 | 1365.2 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 594.8 | 533.8 | 434.9 | 395.5 | 406.7 | 537.0 | 431.0 | 411.7 | 422.3 | 459.3 | 451.0 | 424.7 |
| សណ្តែកសៀង (US No.1) - USA (ដុល្លារ/តោន) | 591.4 | 538.4 | 491.8 | 390.4 | 405.7 | 419.1 | 385.7 | 395.3 | 399.7 | 418.3 | 435.6 | 390.6 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 109.5 | 105.9 | 96.2 | 49.6 | 40.7 | 52.0 | 47.9 | 52.8 | 59.4 | 64.7 | 71.9 | 74.2 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 74.6 | 71.2 | 65.6 | 41.0 | 35.2 | 41.0 | 40.3 | 44.4 | 45.0 | 47.9 | 53.3 | 54.1 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 80.7 | 78.4 | 71.5 | 41.7 | 34.8 | 41.4 | 39.0 | 45.2 | 48.2 | 51.0 | 55.6 | 56.6 |

Sources: Food and Agriculture Organisation; US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៨ ការអនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ បានថយចុះអស់ ៥៥,៥% ដល់ ១.០៥៨.៩លានដុល្លារ ធៀបនឹងត្រីមាសមុន ពោលគឺ ក្នុងវិស័យសេវាកម្ម វាបានធ្លាក់ចុះ ៧២% ដល់ ៦០៥,៥លានដុល្លារ ប៉ុន្តែក្នុងវិស័យកសិកម្ម វាកើន ៤៨% ដល់ ៤៥,២លានដុល្លារ។ ក្នុងវិស័យឧស្សាហកម្ម វាកើនដល់ ៤០៨,២លានដុល្លារ ធៀបនឹង ១៩៣,៤លានដុល្លារ នៅត្រីមាសមុន ប៉ុន្តែនៅទាបជាងត្រីមាសដូចគ្នាឆ្នាំមុនដែលមានដល់ ៤៨៨,៦លានដុល្លារ។

ចំនួនភ្ញៀវទេសចរណ៍មកដល់សរុបមានដល់ ១.៣៧៤.៣៧៣ នាក់នៅត្រីមាសទី៣ ឆ្នាំ២០១៨ ឬកើន ១២,៨% ធៀបនឹងត្រីមាសមុន និង កើន ៩,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ភ្ញៀវទេសចរណ៍ចិន តំណាងឲ្យ ៣៤,៥% នៃភ្ញៀវទេសចរណ៍សរុប បន្ទាប់មកគឺ ភ្ញៀវកូរ៉េខាងត្បូង (៣២,៨%) វៀតណាម (១៣,៤%) ថៃ(៥,១%) ម៉ាឡេស៊ី (៣,៣%) ជប៉ុន (៣,២%) សហរដ្ឋអាមេរិក (៣,២%) បារាំង (២,៣%) និង អង់គ្លេស (២,២%)។

ក្នុងត្រីមាសទី៣ នេះដែរ ការនាំចេញសរុបមានដល់ ៣.៨១៣,៧ លានដុល្លារ ឬកើន ២៣,១% ធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ២៧,១% ធៀបនឹងត្រីមាសមុន។ ដោយឡែក ការនាំចេញសម្លៀកបំពាក់កើនដល់ ២.៨៧១លានដុល្លារ ឬកើន ២៨,១% ធៀបនឹងត្រីមាសមុន។ ធៀបនឹងត្រីមាសមុន ការនាំចេញទៅសហរដ្ឋអាមេរិកកើន ២៩,៦% ដល់ ៧៤៣,៥ លានដុល្លារ ទៅសហភាពអឺរ៉ុបកើន ១៣,៨% ដល់ ៩១៦,៧ លានដុល្លារ, ទៅអាស៊ានកើន 0.៩% ដល់ ៣៣,០លានដុល្លារ, ទៅជប៉ុនកើន ៦៧,៤% ដល់ ២៧៦,៦លានដុល្លារ, ទៅអង់គ្លេសកើន ៨៧,៦% ដល់ ៣៨២,៥លានដុល្លារ និង ទៅប្រទេសផ្សេងទៀតក្នុងពិភពលោក កើន ១២,៨% ដល់ ៥១៨,៨លានដុល្លារ។ ការនាំចេញគ្រឿងអេឡិចត្រូនិក រួមចុះ ៨.៣% ធៀបនឹងត្រីមាសមុន ប៉ុន្តែការនាំចេញគ្រឿងបង្គុំរថយន្តកើន ១៦,៩%។ ការនាំចេញផលិតផលកសិកម្មកើនដល់ ២១៣,៦លានដុល្លារ ឬកើន ២៨,៧% ធៀបនឹងត្រីមាសមុន និងកើន ២១,៨% ពីត្រីមាសដូចគ្នាឆ្នាំ២០១៧។ ទំនិញចូលរួមចំណែកចម្បងគេក្នុងកំណើននេះ គឺមាន កៅស៊ូដែលកើន ៦៣,៧% ដល់ ៥៦,៧លានដុល្លារ, ឈើដែលកើន ២៣,៦% ដល់ ៣៦,៣លានដុល្លារ និង អង្ករដែលកើន ២៣,៥% ដល់ ៨៨,៣លានដុល្លារ ។ ការនាំចេញត្រីនៅក្នុងត្រីមាសនេះ ធ្លាក់ចុះ ២៧,៣% ដល់ ០,០៨លានដុល្លារ។

ការនាំចូលធ្លាក់ចុះ ១២% ធៀបនឹងត្រីមាសមុន និងចុះ ៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដោយសារ ការនាំចូលជា ទំនិញផ្សេងៗ បានធ្លាក់ចុះ ១៥% ធៀបនឹងត្រីមាសមុន។ ការនាំចូលសាំងកើន ៤៣% ដល់ ៨៧លានដុល្លារ, ម៉ាស៊ូតកើន ៣៩% ដល់ ១៦២លានដុល្លារ, សម្ភារសំណង់កើន ១៧% ដល់ ១៦២,៧លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

ក្នុងត្រីមាសទី៣ឆ្នាំ២០១៨ចំណូលសរុបរបស់រដ្ឋាភិបាលមានដល់ ៤.៦៧០,៣ប៊ីលានរៀល ឬធ្លាក់ចុះ ៨% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ២១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ធៀបនឹងត្រីមាសមុនដែរ ចំណូលចរន្តធ្លាក់ចុះអស់ ៨% ដល់ ៤.៦២៥,៦ ប៊ីលានរៀល ហើយចំណូលពន្ធធ្លាក់ចុះ ៩% ប៉ុន្តែ ចំណូលមិនមែនពន្ធកើន ០,៩% ។

ចំណាយសរុបកើន ២៥% ធៀបនឹងត្រីមាសមុន ដល់ ៥.៨៦១,៤ប៊ីលានរៀល និងកើន ២៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ចំណាយមូលធនកើន ៣០% ធៀបនឹងត្រីមាសមុន និង កើន ៤៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដល់ ១.៩៧៨,៣ ប៊ីលានរៀល។

នៅត្រីមាសទី៣ឆ្នាំ២០១៨ប្រតិបត្តិការថវិកាជាតិមានឱនភាពរហូតដល់ ១.១៩១,១ប៊ីលានរៀល ប៉ុន្តែបានល្អប្រសើរឡើង ៦៤% ហើយ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សរុប (CPI) នៅភ្នំពេញមានកម្រិត ២,៥% ធៀបនឹង ២,៧% នៅត្រីមាសមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា បានកើន ២,៥% ហើយ ថ្លៃដឹកជញ្ជូនកើន ៣,៣% ពីមួយឆ្នាំទៅមួយឆ្នាំ។

បើធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារដល់ ៤.០៧៣,៧រៀល ប៉ុន្តែឡើងថ្លៃ ២,៥% ទល់នឹងប្រាក់បាតថៃ ដល់ ១២៤,២រៀល/បាត និងឡើងថ្លៃ ១,១% ទល់នឹងប្រាក់ដុងវៀតណាម ដល់ ១៧,៧រៀល/១០០ដុង។

មាសឡើងថ្លៃ ៧.៣% ដល់ ១៤៦,១ដុល្លារ/ជី។ ម៉ាស៊ូតធ្លាក់ថ្លៃ ៣,៤% ដល់ ៣.៧៨៤ រៀល/លីត្រ ហើយថ្លៃសាំងធ្លាក់ថ្លៃ ២,៩% ដល់ ៤.០០៣រៀល/លីត្រ។

## ស្ថានភាពក្រីក្រ

ផ្នែកនេះពិពណ៌នាពីស្ថានភាពរបស់ពលករងាយរងគ្រោះ និង កម្មករកាត់ដេរ ដោយផ្អែកតាមអង្កេតលើពលករងាយរងគ្រោះចំនួន ៣៦២នាក់ នៅខែវិច្ឆិកា ២០១៨។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើន ៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ១៥.៤៥៤រៀល។ ក្នុងចំណោមអ្នកលីសែងមាន ៨៨% ធ្វើចំណាកស្រុកតែម្នាក់ឯងមកធ្វើការនៅភ្នំពេញ និង មាន ៤៥% មកពីខេត្តព្រៃវែង និង ៣៧% មកពីខេត្តស្វាយរៀង។ ពួកគាត់ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ចំណូលភាគច្រើនរបស់អ្នកលីសែង បានយកទៅចំណាយលើស្បៀងអាហារ (៧៧%) ថ្លៃជួលកន្លែងស្នាក់នៅ (១៤%) ការថែទាំសុខភាព

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

(១%) និងចំណាយផ្សេងៗទៀត (៨%)។ ពលករ ៩៥% បានប្រាប់ថា ចំណូលរបស់ខ្លួនអាចផ្គត់ផ្គង់គ្រួសារបានមួយកម្រិត។

អ្នកលក់បន្លែតូចតាចមានប្រាក់ចំណូលកើនដល់ ២១.០១៨ រៀល/ថ្ងៃ ឬ ៣១,២% ច្រើនជាងកាលពីមួយឆ្នាំមុន។ អ្នកទាំងនេះមានមកពី ខេត្តកណ្តាល (២៥,០%) ស្វាយរៀង (៣៧,៥%) ព្រៃវែង (១៧,៥%) កំពង់ស្ពឺ (២,៥%) កំពត (៥.០%) និង តាកែវ (៧,៥%)។ ពួកគាត់ ៤០% មានដីតិចជាង ១ហិកតា, ៣៧,៥% មានដីពី ១ហិកតា ដល់ ២,៥ហិកតា និង ២២,៥% គ្មានដីធ្លីទេ។ ពួកគាត់គ្រប់គ្នាជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។

អ្នករើសអេតចាយមានចំណូលកើន ១៧,៤% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១២.៥៧០រៀល។ អ្នករើសអេតចាយ ៦៥% បានប្រាប់ថា អេតចាយបានឡើងថ្លៃ ក្នុងបីខែកន្លងមកនេះ។ ពួកគាត់ ៨៥% ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ហើយមាន ៩២,៥% បានប្រាប់ថា ប្រាក់ចំណូលរបស់គាត់អាចផ្គត់ផ្គង់គ្រួសារបានមួយកម្រិត។ ប្រាក់ចំណូលនេះ ពួកគាត់ចំណាយជាសំខាន់លើស្បៀងអាហារ (៦៦%) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (២០%) ការថែទាំសុខភាព (២%) និង ចំណាយផ្សេងៗ (១២%)។

ចំណូលប្រចាំថ្ងៃរបស់ អ្នករត់តុភោជនីយដ្ឋាន ថយចុះ ១,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៨.៣៤៦រៀល។ ពួកគាត់ជាមធ្យមបានធ្វើការជាអ្នករត់តុ ៤ ឆ្នាំមកហើយ។ ម្យ៉ាងទៀត មាន ៤០% ត្រូវធ្វើការ ៨ម៉ោងក្នុងមួយថ្ងៃ ហើយក្រៅពីនោះធ្វើការ ១៤ ម៉ោងក្នុងមួយថ្ងៃ។ ចំណូលរកបាននេះ ពួកគាត់ចំណាយអស់ ៨០,៥% លើស្បៀងអាហារ ៤,០% លើកន្លែងស្នាក់នៅ និង ១៥,៥% លើចំណាយផ្សេងៗទៀត។

ប្រាក់ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែមានត្រឹម ៨.៩៨៤រៀលក្នុងមួយថ្ងៃ ឬ ធ្លាក់ចុះ ១០,៤% ធៀបនឹងកាលពីមួយឆ្នាំមុន។ អ្នកឆ្លើយសម្ភាសន៍ ៦៥% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ពួកគាត់ទាំងអស់គ្នារាយការណ៍ថា ការឡើងថ្លៃស្បៀងអាហារបានប៉ះពាល់ការរស់នៅរបស់គាត់។ ក្នុងចំណោមពួកគាត់មាន ៥៥% ជាប់បំណុលគេ ហើយត្រូវបង់ការប្រាក់តាមអត្រាប្រមាណ ១,០% ក្នុងមួយខែ។

កម្មករសំណង់គ្មានជំនាញ មានចំណូលប្រចាំថ្ងៃថយចុះ ៧,៣% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៨.៩០០រៀល។ អ្នកឆ្លើយសម្ភាសន៍ស្ទើរគ្រប់គ្នា មិនអាចសន្សំប្រាក់បានគ្រប់គ្រាន់សម្រាប់ធ្វើផែនការទៅអនាគតឡើយ។ ប្រាក់ចំណូលនេះ ពួកគាត់ត្រូវចំណាយស្ទើរអស់ទៅវិញ លើស្បៀងអាហារ (៧៧,០%) កន្លែងស្នាក់នៅ (៩,០%) មធ្យោបាយធ្វើដំណើរ (០,១%) សុខភាព (១,៥%) និង ចំណាយផ្សេងៗទៀត (១២,០%)។

តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១២-១៨

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 Q1 | 2017 Q2 | 2017 Q3 | 2017 Q4 | 2018 Q1 | 2018 Q2 | 2018 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 531.6 | 930.5 | 56.5 | 169.8 | 117.1 | 8.0 | 54.9 | - | - | 99.5 | 30.4 | 45.2 |
| ឧស្សាហកម្ម | 829.3 | 3257.0 | 1002.5 | 1014.7 | 1436.4 | 115.6 | 265.7 | 486.6 | 114.3 | 259.6 | 193.4 | 408.2 |
| *. កាត់ដេរ* | 497.0 | 324.1 | 393.5 | 225.2 | 380.7 | 54.0 | 22.0 | 78.9 | 56.3 | 53.2 | 31.4 | 49.9 |
| សេវាកម្ម | 916.6 | 140.7 | 622.6 | 2734.4 | 1664.3 | 7.8 | 1332.0 | 2518.8 | 0 | 110.2 | 2156.2 | 605.5 |
| *. សណ្ឋាគារ និងទេសចរណ៍* | 691.5 | 106.0 | 446.9 | 98.6 | 1366.9 | 3.6 | 237.2 | 2518.8 | 0 | 75.2 | 106.6 | 68.3 |
| សរុប | 2278.0 | 4328.0 | 1583.9 | 3918.9 | 3217.7 | 131.4 | 1652.6 | 3005.4 | 114.3 | 469.3 | 2380.0 | 1058.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -74.1 | 1158.0 | 81.9 | -96.2 | 310.5 | 407.2 | -55.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 90.1 | 63.4 | 147.4 | -67.5 | - | 90.1 | 98.8 | 214.5 | -77.5 | 257.2 | 44.0 | -64.8 |

Note: Including expansion project approvals. Source: Cambodian Investment Board

តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 Q1 | 2014 Q2 | 2014 Q3 | 2014 Q4 | 2015 Q1 | 2015 Q2 | 2015 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | - | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | - | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | - | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១២-១៨

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 Q1 | 2017 Q2 | 2017 Q3 | 2017 Q4 | 2018 Q1 | 2018 Q2 | 2018 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 333.9 | 463.1 | 560.3 | 694.7 | 830.0 | 273.0 | 362.0 | 206.4 | 369.4 | 505.9 | 425.8 | 509.0 |
| វៀតណាម | 763.1 | 854.1 | 905.8 | 987.8 | 959.7 | 203.4 | 267.3 | 122.8 | 241.9 | 186.8 | 199.9 | 197.7 |
| កូរ៉េខាងត្បូង | 411.5 | 435.0 | 424.4 | 395.3 | 357.2 | 127.7 | 87.7 | 41.1 | 88.6 | 126.1 | 48.5 | 483.9 |
| ថៃ | 201.4 | 221.3 | 279.5 | 349.9 | 398.1 | 95.9 | 99.5 | 47.5 | 152.1 | 83.7 | 76.1 | 75.5 |
| សហរដ្ឋអាមេរិក | 173.1 | 185.0 | 191.4 | 217.5 | 238.7 | 80.1 | 76.2 | 29.2 | 71.1 | 79.1 | 54.6 | 47.7 |
| ជប៉ុន | 179.3 | 206.9 | 215.8 | 193.3 | 191.6 | 60.2 | 51.4 | 35.3 | 56.4 | 59.0 | 38.7 | 47.7 |
| បារាំង | 121.2 | 131.5 | 141.1 | 145.7 | 150.3 | 54.0 | 43.2 | 21.5 | 47.7 | 56.6 | 29.4 | 33.5 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចក្រភពអង់គ្លេស | 110.2 | 123.9 | 133.3 | 154.3 | 159.5 | 54.6 | 48.2 | 20.6 | 47.7 | 51.2 | 33.7 | 33.0 |
| ម៉ាឡេស៊ី | 116.8 | 130.7 | 144.4 | 149.4 | 152.8 | 37.8 | 53.4 | 31.8 | 56.4 | 44.8 | 41.0 | 49.4 |
| តាមផ្លូវអាកាស | 1722.1 | 2017.7 | 2273.5 | 2476.0 | 1995.5 | 921.4 | 684.3 | 777.7 | 929.3 | 2308.7 | 2004.1 | 954.8 |
| តាមផ្លូវគោក និងទឹក | 1862.2 | 2192.5 | 2229.3 | 2299.2 | 2331.4 | 581.5 | 475.5 | 472.3 | 760.1 | 1138.0 | 997.5 | 419.6 |
| សរុប | 3584.3 | 4210.2 | 4502.8 | 4775.2 | 4980.4 | 1502.9 | 1159.8 | 1250.1 | 1689.4 | 3446.7 | 3001.7 | 1374.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -0.03 | -22.8 | 7.3 | 35.1 | 104.0 | -12.9 | -54.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 24.4 | 17.5 | 7.0 | 6.1 | 4.3 | 11.9 | 3.9 | 22.7 | 12.4 | 129.3 | -158.8 | 9.9 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១២-១៨*

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 6106.4 | 6982.4 | 8106.0 | 9256.4 | 10043.3 | 2290.7 | 2558.4 | 3098.3 | 2825.6 | 2834.6 | 3000.2 | 3813.7 |
| កាត់ដេរ | 5015.4 | 5386.1 | 5960.5 | 6827.0 | 7308.0 | 1856.3 | 1874.1 | 2290.3 | 1999.6 | 2092.1 | 2240.6 | 2871.0 |
| - *សហរដ្ឋអាមេរិក* | 2143.3 | 2075.2 | 1963.6 | 2009.4 | 1831.5 | 452.3 | 426.0 | 570.8 | 474.7 | 538.4 | 573.9 | 743.5 |
| - *សហភាពអឺរ៉ុប* | 1716.9 | 1969.6 | 2403.7 | 2903.9 | 2928.7 | 583.0 | 693.3 | 787.9 | 718.1 | 670.1 | 805.2 | 916.7 |
| - *អាស៊ាន* | 39.4 | 60.2 | 83.3 | 103.4 | 98.4 | 24.2 | 29.0 | 24.2 | 29.6 | 28.6 | 32.7 | 33.0 |
| - *ជប៉ុន* | 188.6 | 278.7 | 383.1 | 524.2 | 655.5 | 196.2 | 136.7 | 204.8 | 163.6 | 224.7 | 165.2 | 276.6 |
| - *ចក្រភពអង់គ្លេស* | - | - | - | - | 439.8 | 214.2 | 201.6 | 267.0 | 221.2 | 219.5 | 203.9 | 382.5 |
| - *ប្រទេសផ្សេងៗ* | 927.2 | 1002.9 | 1126.8 | 1286.3 | 1354.2 | 386.4 | 387.6 | 435.7 | 392.5 | 410.9 | 459.7 | 518.8 |
| គ្រឿងអេឡិចត្រូនិក | - | - | - | - | - | 127.1 | 73.9 | 82.17 | 96.87 | 76.2 | 90.9 | 83.4 |
| គ្រឿងយានយន្ត | - | - | - | - | - | 1.8 | 6.89 | 1.14 | 1.76 | 11.9 | 13.1 | 15.3 |
| កសិកម្ម | 376.7 | 554.5 | 624.4 | 548.8 | 534.1 | 201.0 | 144.2 | 175.4 | 185.9 | 205.9 | 166.0 | 213.6 |
| - *កៅស៊ូ* | 176.6 | 175.2 | 153.9 | 165.4 | 165.3 | 66.1 | 65.2 | 71.7 | 70.5 | 52.4 | 36.5 | 59.7 |
| - *ឈើ* | 36.8 | 73.6 | 132.0 | 46.3 | 47.2 | 11.7 | 28.9 | 24.6 | 35.3 | 30.0 | 34.0 | 42.0 |
| - *ត្រី* | 2.0 | 1.2 | 0.8 | 0.5 | 0.6 | 0.2 | 0.1 | 0.1 | 0.2 | 1.0 | 0.1 | 0.1 |
| - *អង្ករ* | 146.4 | 262.3 | 248.5 | 315.3 | 300.8 | 83.1 | 35.0 | 66.5 | 70.5 | 106.7 | 71.8 | 88.7 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 14.9 | 42.4 | 89.1 | 21.3 | 20.2 | 39.9 | 15.0 | 12.4 | 9.4 | 15.8 | 23.6 | 23.2 |
| ផ្សេងៗ | 714.4 | 1088.2 | 1520.1 | 1880.2 | 2201.2 | 104.5 | 459.3 | 549.3 | 541.5 | 448.6 | 489.6 | 630.4 |
| ការនាំចូលសរុប | 8593.3 | 8639.4 | 10,295.4 | 11494.5 | 15013.4 | 3173.5 | 5914.4 | 4303.3 | 3424.2 | 4244.5 | 4496.0 | 3976.5 |
| សាំង | 308.0 | 306.4 | 334.7 | 377.3 | 384.8 | 75.1 | 57.5 | 58.3 | 65.8 | 64.9 | 60.8 | 87.0 |
| ម៉ាស៊ូត | 559.5 | 569.1 | 602.3 | 607.8 | 709.1 | 146.4 | 111.1 | 113.3 | 102.2 | 102.0 | 116.9 | 162.0 |
| សម្ភារសំណង់ | 66.1 | 80.8 | 117.6 | 164.4 | 253.2 | 55.6 | 90.3 | 89.6 | 68.8 | 100.7 | 138.7 | 162.7 |
| ផ្សេងៗ | 7659.1 | 7682.6 | 9240.7 | 10345.1 | 13666.3 | 2896.4 | 5655.5 | 4042.2 | 3187.5 | 3976.9 | 4179.7 | 3564.8 |
| ជញ្ជីងពាណិជ្ជកម្ម | -1341.6 | -1610.9 | -2184.3 | -2238.1 | -4470.0 | -641,9 | -3287.6 | -1205.0 | -598.7 | -1409,9 | -1495.9 | -162.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 5.6 | 1.0 | 22.2 | -12.7 | 4.6 | 7.1 | 28.1 |
| ការនាំចេញសរុប | - | - | - | - | - | -6.7 | 14.7 | 17.9 | -8.8 | 0.3 | 5.8 | 27.1 |
| ការនាំចូលសរុប | - | - | - | - | - | 3.0 | 86.4 | -27.2 | -20.4 | 24.0 | 5.9 | -11.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 17.7 | 7.4 | 10.7 | 14.5 | 7.0 | 5.5 | 9.1 | 10.5 | 13.7 | 12.7 | 19.6 | 25.4 |
| ការនាំចេញសរុប | 16.1 | - | - | 14.2 | 8.5 | -4.1 | 10.2 | 10.0 | 15.1 | 23.7 | 14.2 | 23.1 |
| ការនាំចូលសរុប | 19.7 | 21.4 | 19.2 | 11.7 | 30.6 | 14.2 | -3.6 | 42.6 | 11.1 | 33.8 | -24.0 | -7.6 |

Note: Import data include tax-exempt imports.

Sources: Department of Trade Preference Systems, Ministry of Commerce; Customs and Excise Department, Ministry of Economy and Finance website

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១២-១៨ (ប៊ីលានរៀល)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | | | | 2018 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 7691.9 | 8255.2 | 10543.4 | 11879.9 | 14201.5 | 4261.9 | 4093.6 | 3870.8 | 4307.2 | 4357.6 | 5080.6 | 4670.3 |
| ចំណូលចរន្ត | 7443.8 | 8233.2 | 10359.4 | 11759.0 | 14088.7 | 3261.9 | 4071.5 | 3839.2 | 4278.5 | 4344.8 | 5035.2 | 4625.6 |
| ចំណូលពន្ធ | 6334.8 | 7198.1 | 8995.2 | 10502.4 | 12196.5 | 3905.8 | 3580.5 | 3318.4 | 3500.0 | 3984.9 | 4425.4 | 4010.2 |
| ពន្ធក្នុងស្រុក | 5002.8 | 5728.1 | 7226.5 | 8591.7 | 10185.8 | 2450.0 | 3107.5 | 2844.0 | 2928.3 | 3469.8 | 3850.4 | 3424.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1331.7 | 1470.0 | 1822.7 | 1910.7 | 2010.7 | 455.8 | 473.1 | 474.4 | 471.8 | 515.2 | 575.0 | 585.2 |
| ចំណូលមិនមែនពន្ធ | 1118.2 | 1035.2 | 1310.3 | 1256.6 | 1892.2 | 356.2 | 490.9 | 520.9 | 778.5 | 359.8 | 609.8 | 615.4 |
| ចំណូលលើទ្រព្យសម្បត្តិ | 143.0 | 84.0 | 88.5 | 77.3 | 116.0 | 17.4 | 35.8 | 39.1 | 34.9 | 7.7 | 130.5 | 12.6 |
| លក់ទំនិញ និងសេវា | 667.4 | 750.3 | 871.2 | 1047.1 | 1248.3 | 272.1 | 360.3 | 347.3 | 537.0 | 341.0 | 388.9 | 527.8 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.8 | 200.8 | 350.5 | 132.2 | 528.0 | 66.6 | 94.8 | 134.7 | 206.5 | 11.1 | 87.4 | 75.0 |
| ចំណូលជាមូលធន | 247.9 | 73.4 | 184.0 | 121.0 | 113.4 | 0.0 | 22.1 | 31.5 | 28.7 | 12.9 | 45.4 | 44.7 |
| ចំណាយសរុប | 9660.9 | 12,535.7 | 13306.5 | 13849.5 | 13775.4 | 3090.9 | 3878.4 | 4420.9 | 5591.9 | 3583.2 | 4706.2 | 5861.4 |
| ចំណាយជាមូលធន | 3628.3 | 5567.5 | 5590.7 | 5290.3 | 3785.3 | 859.0 | 1096.0 | 1202.1 | 1785.9 | 812.9 | 1517.8 | 1978.3 |
| ចំណាយចរន្ត | 6188.4 | 6968.3 | 7715.8 | 8544.6 | 9990.1 | 2231.9 | 2782.4 | 3218.7 | 3806.0 | 2770.3 | 3188.5 | 3883.1 |
| បៀវត្សរ៍ | 2486.6 | 2997.3 | 3755.5 | 4271.9 | 5381.7 | 1567.6 | 1515.7 | 1739.3 | 1820.2 | 1760.3 | 1911.1 | 2148.8 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1586.8 | 1563.0 | 1627.0 | 1742.9 | 1774.9 | 312.9 | 635.2 | 617.0 | 749.6 | 469.9 | 621.1 | 597.2 |
| ចំណាយចរន្តផ្សេងទៀត | 2115.1 | 2408.0 | 2333.4 | 2529.8 | 2833.5 | 664.3 | 1266.7 | 1479.5 | 1983.8 | 1010.0 | 1277.4 | 1734.4 |
| សមតុល្យជាទូទៅ | -1969.0 | -4280.6 | -2763.1 | -1969.6 | 426.1 | 1171.1 | 215.2 | -550.1 | -1284.8 | 774.5 | 374.4 | -1191.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2457.8 | 4326.2 | 3972.1 | 3729.4 | 1878.9 | 598.5 | 960.8 | 640.6 | 894.1 | 401.6 | 1064.4 | 413.1 |
| ហិរញ្ញប្បទានក្នុងស្រុក | -332.9 | 824.4 | -1428.7 | -2034.9 | -1858.7 | -352.8 | -339.1 | 88.8 | 82.9 | 101.7 | 90.5 | -36.3 |

Source: Ministry of Economy and Finance website

តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១២-១៨

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 Q1 | 2017 Q2 | 2017 Q3 | 2017 Q4 | 2018 Q1 | 2018 Q2 | 2018 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 2.3 | 3.0 | 3.9 | 1.2 | 3.0 | 4.2 | 2.7 | 2.5 | 2.2 | 2.3 | 2.7 | 2.5 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 2.5 | 3.9 | 4.9 | 4.0 | 5.6 | 6.0 | 3.1 | 2.7 | 1.9 | 1.9 | 2.9 | 2.5 |
| - ដឹកជញ្ជូន | 3.3 | -0.6 | -1.0 | -9.2 | -7.0 | 4.1 | 4.3 | 3.8 | 4.1 | 3.1 | 3.9 | 3.3 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4039.2 | 4036.2 | 4060.4 | 4060.4 | 4053.7 | 4015.8 | 4048.2 | 4089.5 | 4036.4 | 4012.4 | 4047.0 | 4073.7 |
| រៀលក្នុង ១ បាតថៃ | 130.0 | 124.9 | 119.4 | 119.4 | 115.5 | 114.9 | 118.8 | 122.8 | 123.4 | 127.7 | 127.4 | 124.2 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.4 | 19.1 | 18.7 | 18.7 | 18.2 | 17.8 | 17.9 | 18.1 | 17.9 | 17.8 | 17.9 | 17.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 200.9 | 175.9 | 152.3 | 140.6 | 151.2 | 145.5 | 150.9 | 154.1 | 155.5 | 160.3 | 157.6 | 146.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4941.2 | 4852.1 | 4934.1 | 3771.3 | 3004.0 | 3391.6 | 3310.4 | 3369.0 | 3472.4 | 3679.0 | 3915.7 | 3784.0 |
| ថ្លៃសាំង (រៀល/លីត្រ) | 5312.7 | 5083.3 | 5155.7 | 3951.7 | 3336.8 | 3697.0 | 3625.2 | 3722.0 | 3819.7 | 3914.0 | 4120.3 | 4003.0 |

Sources: NIS, NBC; CDRI

តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១២-១៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 Q1 | 2017 Q2 | 2017 Q3 | 2017 Q4 | 2018 Q1 | 2018 Q2 | 2018 Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 18154.5 | 21260.1 | 26699.7 | 26665.5 | 31814.5 | 36490.5 | 40285.4 | 43301.5 | 42575.3 | 46707.0 | 49421.9 | 52669.4 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 10437.4 | 11508.3 | 15859.8 | 22157.6 | 25802.3 | 24057.0 | 24985.6 | 26440.4 | 28743.5 | 28457.0 | 29926.1 | 31941.8 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2486.4 | -2794.9 | -4359.1 | -6428.8 | -8148.5 | -9818.9 | -10128.0 | -10347.7 | -11066.5 | -12381.1 | -12887.7 | -12996.4 |
| ឥណទានដល់វិស័យឯកជន | 23536.6 | 27608.8 | 36244.6 | 46071.1 | 56458.8 | 57385.9 | 61189.9 | 63492.6 | 66922.6 | 68686.5 | 72464.2 | 77925.6 |
| រូបិយវត្ថុទូទៅ M2 | 28591.9 | 32768.4 | 42559.5 | 48823.1 | 57616.6 | 60547.4 | 65271.0 | 69741.9 | 71318.9 | 75164.0 | 79348.0 | 84611.3 |
| រូបិយវត្ថុ M1 | 4045.7 | 4878.2 | 6308.4 | 6741.4 | 7273.0 | 7524.7 | 8186.1 | 8925.0 | 9428.4 | 9578.5 | 9553.9 | 10146.0 |
| រូបិយវត្ថុផ្សេងៗ | 18154.5 | 21260.1 | 26699.7 | 42081.7 | 50343.8 | 53022.7 | 57084.8 | 60816.9 | 61890.4 | 65585.5 | 69794.1 | 74465.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 20.9 | 14.6 | 29.9 | 14.7 | 18.0 | 19.0 | 19.7 | 22.1 | 23.8 | 24.1 | 21.6 | 21.3 |
| រូបិយវត្ថុ M1 | 2.3 | 20.6 | 29.3 | 6.9 | 7.9 | 12.2 | 19.1 | 19.6 | 29.6 | 27.3 | 16.7 | 13.7 |
| រូបិយវត្ថុផ្សេងៗ | 44.6 | 13.6 | 30.0 | 16.1 | 19.6 | 20.0 | 19.8 | 22.5 | 22.9 | 23.7 | 22.3 | 22.4 |

Source: National Bank of Cambodia

តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2016 | 2017 | | | | 2018 | | | | 2018 | | |
| | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នករត់ស៊ីក្លូ | 11516 | 11092 | 10916 | 10804 | 10362 | 11042 | 11285 | 10267 | 10503 | 3.4 | -5.0 | 1.3 |
| អ្នកលីសែង | 14318 | 15171 | 14625 | 15423 | 14549 | 15123 | 14915 | 15889 | 15454 | 2.0 | 3.0 | 6.2 |
| អ្នកលក់បន្លែតូចតាច | 17177 | 18411 | 13980 | 19655 | 16015 | 18343 | 20999 | 20141 | 21018 | 50.2 | 2.5 | 31.2 |
| អ្នករើសអេតចាយ | 10297 | 11478 | 12428 | 11754 | 10703 | 10664 | 13931 | 13288 | 12570 | 12.1 | 13.0 | 17.4 |
| អ្នករត់តុភោជនីយដ្ឋាន* | 7989 | 7905 | 8141 | 8135 | 8190 | 8226 | 8077 | 7945 | 8346 | 14.1 | -2.3 | 1.8 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8088 | 8332 | 7049 | 8708 | 8132 | 8774 | 8486 | 8427 | 8984 | 6.6 | -3.2 | 10.4 |
| កម្មកររោងចក្រកាត់ដេរ | 13688 | 14889 | 12910 | 14299 | 14275 | 15268 | 14605 | 15316 | - | 3.9 | 7.1 | ** |
| អ្នករត់ម៉ូតូឌុប | 14509 | 14770 | 13888 | 14370 | 13895 | 14901 | 14429 | 15293 | 14637 | 6.6 | 6.4 | 5.3 |
| កម្មករសំណង់គ្មានជំនាញ | 17365 | 16664 | 14796 | 17533 | 20371 | 18082 | 15771 | 17539 | 18900 | 6.6 | 0.0 | -7.3 |
| កម្មករសំណង់មានជំនាញ | 20008 | 21716 | 21924 | 23014 | 24951 | 25578 | 25025 | 23276 | 26595 | 14.1 | 1.1 | 6.5 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. **Not available. Source: CDRI

## *តពីទំព័រ ១២* ស្ថានភាពក្រៅប្រទេស

១.៥០៤,០ដុល្លារ/តោននៅត្រីមាសទី១ រហូតដល់ ១.៤៣៣,៣ ដុល្លារ/តោននៅត្រីមាសទី២ និងដល់ ១.៣៦៥,២ដុល្លារ/តោននៅត្រីមាសទី៣។ ក្នុងពេលជាមួយគ្នា អង្ករក៏ធ្លាក់ថ្លៃជាខ្លាំងដល់ ៤២៤,៧ដុល្លារ/តោននៅត្រីមាសទី៣ ដោយចុះពី ៤៥១,០ ដុល្លារ/តោន ធៀបនឹង ៤៥៩,២ដុល្លារ/តោននៅត្រីមាសទី១ និង ៤៥១,០ដុល្លារ/តោន នៅត្រមាសទី២។ ថ្លៃពោតស្ថិតនៅកម្រិតទាបបំផុត ដោយបានកើនពី ១៦៣,៧ដុល្លារ/តោននៅត្រីមាសទី១ ដល់ ១៧៣,៣ដុល្លារ/តោននៅត្រីមាសទី២ ប៉ុន្តែធ្លាក់ចុះដល់ ១៥៧,៩ដុល្លារ/តោននៅត្រីមាសទី៣។ ថ្លៃប្រេងដូងប្រេងធ្លាក់ចុះពី ៦៧៣,៧ដុល្លារ/តោននៅត្រីមាសទី១ ដល់ ៦០១,០ដុល្លារ/តោននៅត្រីមាសទី២ រួចកើនវិញបានខ្លះ ដល់ ៦១២,០ដុល្លារ/តោននៅត្រីមាសទី៣។ ថ្លៃសណ្តែកសៀងធ្លាក់ចុះដល់ ៣៩០,៦ ដុល្លារ/តោននៅត្រីមាសទី៣ បន្ទាប់ពីកើនឡើងដល់ ៤១៨,៣ ដុល្លារ/តោននៅត្រីមាសទី១ និងដល់ ៤៣៥,៦ដុល្លារ/តោននៅត្រីមាសទី២។

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ...**

និងបានផ្ដល់មតិមួយចំនួនពី ជម្រើសគោលនយោបាយ និងយុទ្ធសាស្ត្រ សម្រាប់ជំរុញចំណងទាក់ទងស្រដៀងគ្នាដែរនៅកម្ពុជា។

ថ្ងៃទី ២០ ធ្នូ ភ្នំពេញ

**សិក្ខាសាលាពិគ្រោះយោបល់លើ ព្រឹត្តិប័ត្រព័ត៌មានបច្ចេកវិទ្យាកសិកម្ម៖** សិក្ខាសាលានេះ បានរៀបចំឡើងដោយរួមសហការជាមួយអង្គការ Swiss Contact ដើម្បីចាប់ផ្ដើមដំណើរការ ព្រឹត្តិប័ត្រព័ត៌មានបច្ចេកវិទ្យាកសិកម្ម ដែលផ្នែកកសិកម្មនៃ CDRI រៀបចំឡើងដោយផ្អែកលើទិន្នន័យដ៏សម្បូរប្រមូលបានតាមរយៈការស្រាវជ្រាវអង្កេត។

## ការស្រាវជ្រាវ

### *ផ្នែកកសិកម្ម*

ក្រុមការងារកំពុងអនុវត្តគម្រោង ចំនួន ៧។ គម្រោង *ការសាកល្បងយន្តការបែបថ្មី សម្រាប់ការផ្សព្វផ្សាយកសិកម្មនៅកម្ពុជា* ដែលផ្ដល់មូលនិធិដោយ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) បានចប់សព្វគ្រប់ដោយមានសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិមួយនៅខែធ្នូ។ ការវិភាគទិន្នន័យ និងការសរសេររបាយណ៍ការសម្រាប់គម្រោង *ការអនុវត្តស្តង់ដាសុវត្ថិភាពក្នុងសាកវប្បកម្មនៅកម្ពុជា៖ ករណីដំណាំបន្លែ* ដែលទទួលបានមូលនិធិពី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) មិនទាន់ដំណើរការឡើងវិញទេ។ នៅខែធ្នូ ផ្នែកនេះបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយ ដើម្បីទទួលបានធាតុចូលសម្រាប់ ព្រឹត្តិប័ត្រព័ត៌មានបច្ចេកវិទ្យាកសិកម្មប្រចាំត្រីមាស ដែល CDRI កំពុងរៀបចំដោយមានជំនួយគាំទ្រផ្នែកបច្ចេកទេសពី អង្គការ Swiss Contact Cambodia។ ការអនុវត្តសាកល្បងដើម្បីរចនារៀបចំឲ្យស្រេចបាច់នូវ ឧបករណ៍សម្រាប់ធ្វើអង្កេតក្នុង គម្រោង *ការវិភាគខ្សែសង្វាក់តម្លៃផ្លែស្វាយ* ដែលផ្ដល់មូលនិធិដោយ Sida បានដំណើរការគួរឲ្យពេញចិត្ត។ ការងារបានចាប់ផ្ដើមលើគម្រោងថ្មី ៣ ស្ដីពី ១) *ផលត្រឡប់ផ្នែកសេដ្ឋកិច្ចនៃវិនិយោគក្នុង ការអប់រំ និងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ការកសាងសមត្ថភាពបម្រើការងារ និងសហគ្រិនភាពរបស់យុវជននៅកម្ពុជា* ដែលផ្ដល់មូលនិធិដោយ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ២) *ចំណាកស្រុក ការផ្ញើប្រាក់ទៅផ្ទះ និងការចូលរៀនរបស់កុមារនៅជនបទកម្ពុជា* ដែលផ្ដល់មូលនិធិដោយ អង្គការភាពជាដៃគូ សម្រាប់គោលនយោបាយផ្នែកសេដ្ឋកិច្ច (Partnership for Economic Policy) និង ៣) ការវាយតម្លៃលទ្ធផលពាក់កណ្ដាលអាណត្តិលើគម្រោង *HARVEST II* (ការជួយដោះស្រាយភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពប្រព័ន្ធអេកូឡូស៊ី) ដែលផ្ដល់មូនិធិដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដោយរួមសហការជាដៃគូជាមួយក្រុមហ៊ុន Mitchell Group, Inc។

### *ផ្នែកសេដ្ឋកិច្ច*

សម្រាប់គម្រោង *ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈ (VSD) ដល់កំណើន និងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគលើកត្តាសំខាន់ៗនៅកម្ពុជា* គឺការចុះសិក្សាដល់កន្លែងលើ ប្រមាណ ១១០ក្រុមហ៊ុន បានចាប់ផ្ដើមនៅខែតុលា ហើយរំពឹងថានឹងចប់សព្វគ្រប់នៅខែមករា ២០១៩។

សិក្ខាសាលាបណ្ដុះបណ្ដាល វិធីសាស្ត្រស្រាវជ្រាវសម្រាប់គម្រោង *ពាណិជ្ជកម្មផ្នែកកសិកម្មរវាងប្រទេសចិន នឹងបណ្ដាប្រទេសនៅតំបន់មេគង្គឡានឆាង៖ ការវិភាគខ្សែសង្វាក់តម្លៃ* បានធ្វើឡើងនៅខែតុលា។ សម្រាប់ការបណ្ដុះបណ្ដាលដែលផ្ដោតលើការរចនារៀបចំការស្រាវជ្រាវ និងឧបករណ៍សម្រាប់ការវិភាគខ្សែសង្វាក់តម្លៃ បណ្ឌិត Raymond Trewin មកពីសាលាគោលនយោបាយសាធារណៈ Crawford នៃសាកលវិទ្យាល័យជាតិអូស្ត្រាលី (ANU) បានមកជួយបង្រៀន ហើយ បណ្ឌិត Jayant Menon ប្រធានក្រុមសេដ្ឋវិទូ នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានជួយផ្ដល់មតិណែនាំ។ ការចុះសិក្សាដល់កន្លែងសម្រាប់គម្រោងរួមគ្នាជាមួយផ្នែកបរិស្ថាន ស្ដីពី *ការឆ្លើយតបរបស់ប្រជាជនទៅនឹង ការប្រែប្រួលបរិស្ថាននៅអាងទន្លេមេគង្គក្រោម* ដែលទទួលបានជំនួយគាំទ្រពី មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រសង្គមអន្តរជាតិ នៃសាកលវិទ្យាល័យឈីកាហ្គោ បានចាប់ផ្ដើមនៅសប្ដាហ៍ទី១ ក្នុងខែធ្នូ។

គម្រោងចំនួនពីរបានចប់សព្វគ្រប់នៅខែធ្នូ ២០១៨ គឺមាន ១) *កិច្ចសហប្រតិបត្តិការមេគង្គឡានឆាង និងការរីកលូតលាស់វាយនភ័ណ្ឌ និងខ្សែសង្វាក់តម្លៃសម្លៀកបំពាក់ក្នុងតំបន់* និង ២) *ឌីណាមិកនៃភាពក្រីក្រ៖ ករណីសិក្សានៅប្រទេសកម្ពុជា*។ ការសិក្សាតាមរយៈឯកសារ ស្ដីពី *ឧស្សាហកម្ម ៤.០៖ ការប្រមើលឃើញ និងបញ្ហាប្រឈមសម្រាប់វិស័យកម្មន្តសាលនៅកម្ពុជា* បានចប់រួចរាល់ និងបានបោះពុម្ពផ្សាយជា អត្ថបទសង្ខេបស្រាវជ្រាវមួយរបស់ CDRI ក្នុងខែវិច្ឆិកា ២០១៨។ ផ្នែកនេះបានរចនារៀបចំការសិក្សាមួយស្ដីពី *អ្នកលក់ដូរតាមដងផ្លូវ ការងាររបស់យុវជន និងការកាត់បន្ថយភាពក្រីក្រ* នៅក្នុងកម្មវិធីស្រាវជ្រាវរយៈពេលប្រាំឆ្នាំផ្ដល់មូលនិធិដោយ Sida ស្ដីពីការអភិវឌ្ឍឧស្សាហកម្ម មូលធនមនុស្ស និងការអភិវឌ្ឍសហគ្រាសខ្នាតតូចនិងមធ្យម (SME) នៅកម្ពុជា។ កិច្ចព្រមព្រៀងផ្ដល់អំណោយថវិកាថ្មីមួយសម្រាប់ការសិក្សាពី *ផលប៉ះពាល់នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ទៅលើការអភិវឌ្ឍកសិអាជីវកម្មនៅកម្ពុជា* ត្រូវបានចុះហត្ថលេខារវាង វិទ្យាស្ថាន CDRI និង វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មនៅប្រទេសឡាវ (IRIT - Lao)។

សេដ្ឋវិទូជាន់ខ្ពស់ម្នាក់បានលើកបង្ហាញពី លទ្ធផលការស្រាវជ្រាវស្ដីពី *ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងការប្រែប្រួលនៃទីផ្សារពលកម្ម៖ ការសិក្សាពិសោធន៍ដោយចៃដន្យក្នុងចំណោមយុវជនកម្ពុជាទន់ខ្សោយ* នៅក្នុងសិក្ខាសាលាអន្តរជាតិមួយ

ស្តីពី យេនឌ័រ វិសមភាព និងការងារនៅអាស៊ីអាគ្នេយ៍៖ ការលើកកម្ពស់សមភាពនៅក្នុងបរិយាកាសការងារកំពុងប្រែប្រួល។ សិក្ខាសាលានេះ រៀបចំឡើងដោយ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិកាណាដា ក្នុងខែវិច្ឆិកា នៅក្រុងបាងកក ប្រទេសថៃ។

### *ផ្នែកអប់រំ*

ការប្រមូលទិន្នន័យ សម្រាប់ការសិក្សាពី *ការធ្វើផែនទីពិពិធភាពនៃគ្រឹះស្ថានឧត្តមសិក្សា (HEIs) នៅកម្ពុជា* បានចាប់ផ្តើមនៅចុងខែវិច្ឆិកា បន្ទាប់ពីមានការពិគ្រោះយោបល់លើកទី២ ជាមួយ អគ្គនាយកដ្ឋានឧត្តមសិក្សា នៅថ្ងៃទី២២ តុលា។ ការសិក្សានេះផ្តល់មូលនិធិដោយ ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ដើម្បីលើកកម្ពស់ការពិភាក្សាក្នុងចំណោមអ្នកប្រាជ្ញ អ្នកអប់រំ អ្នកដឹកនាំគ្រឹស្ថានឧត្តមសិក្សា អ្នកកសាងគោលនយោបាយ និងសាធារណជន ហើយប្រមូលភស្តុតាងស្រាវជ្រាវ សម្រាប់ផ្តល់ទៅឲ្យអ្នកកសាងគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀតប្រើប្រាស់ ក្នុងការកែលំអប្រព័ន្ធឧត្តមសិក្សា និងកំណត់កម្រិតគោលសម្រាប់ការបែងចែកប្រភេទ និងការធ្វើចំណាត់ថ្នាក់គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា។ លទ្ធផលនឹងយកទៅចងក្រងធ្វើជា ឯកសារពិភាក្សាមួយរបស់ CDRI។ គម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *សហគ្រិនភាព និងនវានុវត្តន៍សង្គមនៅក្នុងឧត្តមសិក្សា* កំពុងស្ថិតនៅក្នុងដំណាក់កាលវិភាគទិន្នន័យ និងសរសេររបាយការណ៍។

បន្តពីវេទិកា ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (PPP) ដែលធ្វើឡើងនៅខែសីហា ផ្នែកនេះបានរៀបចំ ការប្រជុំបូកសរុបពី PPP កម្រិតខ្ពស់ នៅថ្ងៃទី ២៤-២៥ តុលា នៅក្រុងកែប សម្រាប់អ្នកតំណាងជាន់ខ្ពស់ មកពីក្រុមហ៊ុនឯកជន និងមជ្ឈមណ្ឌលបណ្តុះបណ្តាល បានជ្រើសរើសពីតំបន់ខុសៗគ្នា។ ព្រឹត្តិការណ៍នេះ មានគោលដៅពិភាក្សាពីការអភិវឌ្ឍអាជីវកម្មទៅអនាគតក្នុងវិស័យសំខាន់ៗ និងតម្រូវការជំនាញ និងការបណ្តុះបណ្តាលកម្លាំងពលកម្ម ដើម្បីជួយទ្រទ្រង់កំណើនអាជីវកម្ម និងការប្រែក្លាយសេដ្ឋកិច្ចតាមរយៈ ឧស្សាហកម្ម ៤.០។

កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារលើកទី៣ សម្រាប់កម្មវិធីស្រាវជ្រាវស្តីពី *ការស្រាវជ្រាវ និងការជះឥទ្ធិពលផ្នែកគោលនយោបាយឧត្តមសិក្សានៅកម្ពុជា* បានធ្វើឡើងនៅថ្ងៃទី១៤ ធ្នូ។ គណៈកម្មាធិការនេះដែលរួមមានអ្នកតំណាងមកពី CDRI DFAT ក្រសួងអប់រំ យុវជន និងកីឡា និង Sida បានពិភាក្សាពីដំណើរការជឿនលឿនកម្មវិធីទាំងមូល និងស្វែងរកកិច្ចសហការស្រាវជ្រាវទៅអនាគតទៀត។

ផ្នែកនេះ បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលចំនួនមួយថ្ងៃ ស្តីពីជំនាញប្រាស្រ័យទាក់ទងផ្នែកវិទ្យាសាស្ត្រ នៅថ្ងៃទី ២១ ធ្នូ។ ការបណ្តុះបណ្តាលនេះធ្វើឡើងដោយជំនាញការពីរនាក់មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវនៅដើមអាជីព និងអ្នកស្រាវជ្រាវមានបទពិសោធន៍ច្រើន បានអនុវត្តជាក់ស្តែងនូវ របៀបប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអ្នកពាក់ព័ន្ធផ្សេងៗ។

### *ផ្នែកបរិស្ថាន*

ក្រុមការងារសម្រាប់គម្រោង *ការពង្រឹងសមត្ថភាពស្ត្រីសម្រាប់ភាពធន់នឹងអាកាសធាតុនៅកម្ពុជា* បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់បួនលើកជាមួយភាគីពាក់ព័ន្ធនៅតាមបណ្តាខេត្តគោលដៅ។ ក្រុមស្ត្រីថ្នាក់មូលដ្ឋានចំនួន ១០ក្រុម បានទទួលមូលនិធិខ្នាតតូចពីគម្រោង ដើម្បីអនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់សហគមន៍ ដែលសមស្របតាមស្ថានភាពក្នុងមូលដ្ឋាន និងដែលពួកគាត់បានរចនារៀបចំខ្លួនឯងដោយមានជំនួយគាំទ្រពីអង្គការដៃគូ។

គម្រោង *ការឆ្លើយតបរបស់ប្រជាជនទៅនឹងការប្រែប្រួលបរិស្ថាននៅអាងទន្លេមេគង្គក្រោម* កំពុងមានដំណើរការល្អ។ ក្រុមការងារបានធ្វើការពិភាក្សាតាមក្រុមស្នូល ចំនួន ៦ និង អង្កេតលើបុគ្គល ចំនួន ៣០ នៅក្រុងភ្នំពេញ ជាមួយនឹងពលករចំណាកស្រុកមកពីភូមិលិចទឹកនៅតាមដងទន្លេ។របាយការណ៍សម្រាប់គម្រោងផ្តល់មូលនិធិដោយ Sida ស្តីពី *ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ* កំពុងពិនិត្យឡើងវិញដោយផ្អែកលើ មតិយោបល់បន្ថែមរបស់ទីប្រឹក្សាខាងក្រៅ និងសមាជិកក្រុមអនុវត្តគម្រោង។

ក្រុមស្រាវជ្រាវសម្រាប់គម្រោងកម្រិតតំបន់ ស្តីពី *ការធ្វើកសិកម្មតាមកិច្ចសន្យានៅក្នុងតំបន់មេគង្គឡានឆាង* កំពុងចុះសិក្សាដល់កន្លែងនៅតាមប្រទេសរៀងៗខ្លួន។ក្រុមស្រាវជ្រាវរបស់ CDRI ដោយរួមសហការជាមួយ នាយកដ្ឋានកសិឧស្សាហកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (DAI-MAFF) បានធ្វើសម្ភាសន៍ជាមួយកសិករ ក្រុមហ៊ុន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។ គម្រោង ស្តីពី *ផលប៉ះពាល់នៃ កម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ យេនឌ័រ និងសិទ្ធិមនុស្ស* កំពុងស្ថិតនៅក្នុងដំណាក់កាលត្រៀមការងារ ដោយបានរៀបចំការចុះពិនិត្យដល់កន្លែងនៅខេត្ត កំពង់ចាម និង កំពង់ធំ និងធ្វើការប្រជុំគណៈកម្មាធិការដឹកនាំការងារនិង និងការប្រជុំចាប់ផ្តើមគម្រោង ដើម្បីជំរុញឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធនៅគ្រប់កម្រិត។

### *ផ្នែកអភិបាលកិច្ច*

ផ្នែកនេះ បានបញ្ចប់ឯកសារពិភាក្សាជាភាសាអង់គ្លេស ស្តីពី *យុវជន និងមនុស្សជំនាន់មុននៅកម្ពុជា៖ ទំនាក់ទំនងរវាងជំនាន់ទាំងពីរ និងទស្សនៈសង្គម និងនយោបាយ*។ អ្នកស្រាវជ្រាវម្នាក់បានទៅចូលរួមសិក្ខាសាលា ស្តីពី ឌីណាមិកនៃការវិវត្តអង្គការសង្គមស៊ីវិល នៅឯ សាកលវិទ្យាល័យ Gadjad Mada នៅប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី ២៨ តុលា ដល់ ២ វិច្ឆិកា។ សាស្ត្រាចារ្យរង Cesi Cruz នៃសាកលវិទ្យាល័យ British Columbia បានផ្តល់វគ្គបណ្តុះបណ្តាលមួយថ្ងៃ ស្តីពី វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យសម្រាប់ការវិភាគផ្នែកយេនឌ័រ លើទិន្នន័យអង្កេតយុវជនរបស់ក្រុមស្រាវជ្រាវ។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

ថ្ងៃទី ២២ តុលា ក្រុងភ្នំពេញ

**ការលើកកម្ពស់ភាពចម្រុះក្នុង ឧត្តមសិក្សានៅកម្ពុជា៖** ផ្នែកអប់រំរបស់វិទ្យាស្ថាន CDRI បានធ្វើការជាមួយ អគ្គនាយកដ្ឋានឧត្តមសិក្សា (GDHE) នៃក្រសួងអប់រំ យុវជននិងកីឡាដើម្បីកំណត់លំអិតនូវភាពចម្រុះបែបក្នុងការសិក្សា និងការបង្រៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងទូទាំងប្រទេស។ អ្នកស្រាវជ្រាវផ្នែកអប់រំ និងអ្នកតំណាង GDHE បានពិភាក្សាពីលទ្ធផលរកឃើញដំបូងៗ និងការយល់ដឹងលំអិតផ្នែកគោលនយោបាយ ដែលទទួលបានពីសិក្ខាសាលាពិភាក្សាកំណត់ភាពត្រឹមត្រូវ។ សិក្ខាសាលាត្រូវបានបើកដំណើរការដោយ នាយកប្រតិបត្តិ CDRI (ED)។

ថ្ងៃទី ៣០ តុលា និង ១ វិច្ឆិកា នៅ CDRI ក្រុងភ្នំពេញ

**វគ្គសកម្មខ្លីស្ដីពី វិធីសាស្ត្រស្រាវជ្រាវសម្រាប់ការវិភាគខ្សែសង្វាក់តម្លៃ៖** ការបណ្ដុះបណ្ដាលនេះធ្វើឡើងដោយ បណ្ឌិត Jayant Menon ជាទីប្រឹក្សាគម្រោង និងអតីតសេដ្ឋវិទូជាន់ខ្ពស់នៅធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីកសាងសមត្ថភាពជំនាញ និងគាំទ្រសកម្មភាពរបស់ក្រុមស្រាវជ្រាវ សម្រាប់អនុវត្តគម្រោងស្ដីពីពាណិជ្ជកម្មកសិកម្មរវាងប្រទេសចិន និងបណ្ដាប្រទេសក្នុងតំបន់មេគង្គ-ឡានឆាង៖ វិភាគខ្សែសង្វាក់តម្លៃ។

ថ្ងៃទី ១-២ វិច្ឆិកា ក្រុងស៊ីអាន ខេត្តសានស៊ី ប្រទេសចិន

**សិក្ខាសាលាស្ដីពី ការតភ្ជាប់វិធាន និងស្តង់ដានានា ក្នុងសហប្រតិបត្តិការអន្តរជាតិខ្សែក្រវាត់មួយផ្លូវមួយ៖** សិក្ខាសាលាបានអញ្ជើញមករួមប្រជុំនូវ គណៈប្រតិភូផ្សេងៗប្រមាណ ៥០នាក់ មកពី ប្រទេសចិន បណ្ដាប្រទេសនៅតាមច្រករបៀងក្នុងតំបន់នៃ គំនិតផ្ដួចផ្ដើមខ្សែក្រវាត់មួយផ្លូវមួយ (BRI) និងអង្គការអន្តរជាតិនានា ដើម្បីពិភាក្សាពីបញ្ហាជាប់ទាក់ទងនឹង អនុសញ្ញាប្រឆាំងអំពើពុករលួយ ការផ្ដល់ហិរញ្ញប្បទានមានចីរភាព កិច្ចការពារនិងគ្រប់គ្រងបរិស្ថាន ក្រមសីលធម៌ និងការប្រព្រឹត្តប្រកបដោយសីលធម៌ និងទំនួលខុសត្រូវរបស់ក្រុមហ៊ុន និង ការធ្វើសហប្រតិបត្តិការច្រើនថែមទៀតលើវិធាន និងស្តង់ដាក្នុងតំបន់ BRI។ ក្នុងសិក្ខាសាលានេះ នាយកប្រតិបត្តិ CDRI បានចូលរួមជាវាគ្មិនក្នុងក្រុមបំផុសការពិភាក្សា។

ថ្ងៃទី ៦ វិច្ឆិកា CDRI ក្រុងភ្នំពេញ

**CDRI បើកដំណើរការជាផ្លូវការនូវ មជ្ឈមណ្ឌលសិក្សាពីប្រទេសចិន ទើបបង្កើតថ្មី៖** ភ្ញៀវកិត្តិយសអញ្ជើញមកចូលរួមក្នុងពិធីសម្ពោធន៍ មានជាអាទិ៍ លោក Li Jie ទីប្រឹក្សានៃស្ថានទូតចិននៅកម្ពុជា, បណ្ឌិត ម៉ី កល្យាណ ប្រធានក្រុមប្រឹក្សាភិបាល CDRI និងជា ទីប្រឹក្សាជាន់ខ្ពស់នៃ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, និងអ្នកតំណាងនៃ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត ទីភ្នាក់ងារស៊ុីសសម្រាប់សហប្រតិបត្តិការនិងអភិវឌ្ឍន៍ ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ មជ្ឈមណ្ឌលនេះមានចក្ខុវិស័យដើម្បីក្លាយជា មជ្ឈមណ្ឌលមានសមត្ថភាពខ្ពស់ មានវិជ្ជាជីវៈ និងមានឥទ្ធិពល សម្រាប់ការសិក្សាពីប្រទេសចិននៅកម្ពុជា។

ថ្ងៃទី ១២ ធ្នូ CDRI ក្រុងភ្នំពេញ

**កិច្ចសន្ទនារវាងមជ្ឈដ្ឋានឧស្សាហកម្ម នឹងសាកលវិទ្យាល័យ ស្ដីពី ការស្រាវជ្រាវ ការបង្កើតផលិតផលថ្មី និងនវានុវត្តន៍។** ភ្ញៀវកិត្តិយសបានចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលា មានជាអាទិ៍ សាស្ត្រាចារ្យ Fred Boey អនុប្រធាន (ផ្នែកនវានុវត្តន៍ និងសហគ្រាស) នៃ សាកលវិទ្យាជាតិសិង្ហបុរី (NUS) ដែលបានចែករំលែកដល់អ្នកស្រាវជ្រាវរបស់ CDRI នូវបទពិសោធន៍យ៉ាងច្រើនក្នុងការបង្កើតចំណងទាក់ទងរវាងសាកលវិទ្យាល័យ នឹងសហគ្រាស

*តទៅទំព័រ ១៨*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី២២ លេខ៤ ខែធ្នូ ឆ្នាំ២០១៨

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្ដី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
+៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសម្រួល: យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្ម: អ៊ុំ ចាន់ថា

សហគ្រាសបោះពុម្ព Go Invent Media (GIM), រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ជូនដោយឥតគិតថ្លៃតាមរយៈវេបសាយ www.cdri.org.kh